# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ២ លេខ ១

ខែកញ្ញា ព.ស. ២៤៩៣

ឆ្នាំសិក្សា ១៩៥០-៥១

BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K-2
1950-1951
(1)

# ព្រះរាជអាណាចក្រកម្ពុជា

មន្ទីរស្ដីការ ក្រសួងសិក្សាធិការ

## ទស្សនាវដ្ដី សម្រាប់ គ្រូបង្រៀន

## បញ្ជីរឿង

| | ទំព័រ |
|---|---|
| ឧត្ដមដ្ឋាន ភាសា | ៣ |
| មជ្ឈមដ្ឋានទី១ និងទី២ ភាសា | ៤ |
| អាទិកដ្ឋាន ភាសា | ៨ |
| កុមារដ្ឋាន ភាសា | ១៥ |
| បរិវច្ឆណដ្ឋាន ភាសា | ១៩ |
| ឧត្ដមដ្ឋាន-មជ្ឈិមដ្ឋានទី២-នព្វន្ត-រង្វាស់រង្វាល់-ធរណីមាណសាស្ត្រ | ២២ |
| អាទិកដ្ឋាន មជ្ឈិមដ្ឋាន- នព្វន្ត - | ៣១ |
| អាទិកដ្ឋាន មជ្ឈិមដ្ឋានទី១ រង្វាស់រង្វាល់ ធរណីមាណសាស្ត្រ | ៣៦ |
| បរិវច្ឆណដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ | ៤៦ |
| កុមារដ្ឋាន - នព្វន្ត - រង្វាស់រង្វាល់ | ៥១ |
| មជ្ឈិមដ្ឋានទី ២ - ឧត្ដមដ្ឋាន - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ | ៥៨ |
| អាទិកដ្ឋាន មជ្ឈិមដ្ឋានទី ១ - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ. | ៦៦ |
| កុមារដ្ឋាន - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ | ៧១ |
| បរិវច្ឆណដ្ឋាន - វត្ថុស្វាធ្យាយន៍ - វិធីបង្ការរោគ | ៧៦ |
| មេសូត្រតែមាត់ | ៧៩ |

# ឧត្តមដ្ឋាន

## ១. ការអានសៀវភៅ

នៅនានាប្រទេស គេនិយមរាប់អាន ការអានសៀវភៅ សំខាន់ជាងការ មើលកុន មើលល្ខោន ច្រើនណាស់ ។ ប្រជាជនរបស់គេគ្រប់ថ្នាក់ ច្រើននិយមមើលកាសែតរាល់ថ្ងៃ យ៉ាងហោចណាស់ក៏ម្ដងមួយថ្ងៃពីរច្បាប់ ក្រៅពីនេះនៅនិយមអានសៀវភៅ របស់អ្នកនិពន្ធដែលមានកេរ្តិ៍ឈ្មោះទៀតរាល់ថ្ងៃ ដើម្បីជាបច្ច័យដុសខាត់ខួរក្បាលរបស់គេឲ្យភ្លឺថ្លា ។ ហេតុដូច្នេះ ទើបគេអាចបោះពុម្ពសៀវភៅ ចំណាយចេញទៅរាប់ហ្មឺន រាប់សែនក្បាល ជួនកាលរាប់លានក៏មាន ។

មានតែការអានសៀវភៅប៉ុណ្ណោះទេ ដែលធ្វើឲ្យអ្នកមានខួរក្បាលឈ្លាសវៃទាន់សម័យនិយម ។ សៀវភៅល្អៗ ដែលមានសារប្រយោជន៍អាចនឹងធ្វើជីវិតនិងឋានៈរបស់អ្នកឲ្យបានចំរើនរុងរឿងជាអនេកប្រការ ដូចពួកមហាបុរសក្នុងលោក ធ្លាប់បានប្រព្រឹត្តមកហើយ ។ តែការអានសៀវភៅនេះ ក៏មិនមែនជាការងាយស្រួលដែរ ព្រោះសៀវភៅនិមួយៗរមែងតែងមានទាំងរឿងល្អនិងអាក្រក់ច្របល់គ្នា ទើបមុននឹងអានសៀវ-ភៅអ្វីនោះ គួររើសរកមើលសៀវភៅណាដែលល្អសឹមអាន ព្រោះសៀវ-

ភៅដែលល្អ ៗ ជាឧបាយដាស់តឿនក្រើនរំលឹកចិត្តគំនិតឲ្យទៅជាអ្នកនិពន្ធមានកេរ្តិ៍ឈ្មោះល្បី ឲ្យកើតមនុស្សធំ ឲ្យកើតវិទ្យាសាស្ត្រ ឲ្យកើតមនុស្សសំខាន់ៗ ក្នុងលោក ឯសៀវភៅអាក្រក់វិញនាំឲ្យកើតចិត្តទុច្ចរិត ឃោរឃៅសម្លាប់គេឥតញញើតដៃ ដូច្នេះការជ្រើសរើសមើលសៀវភៅសិនសិមអាន ទើបមានប្រយោជន៍យ៉ាងសំខាន់សម្រាប់ជីវិត ។

ពាក្យពន្យល់ ៖ — ការអាន = ការមើលសៀវភៅ — អ្នកនិពន្ធ= អ្នកតែងសៀវភៅ បច្ច័យ = ហេតុជាទីអាស្រ័យគ្នា ។ មហាបុរស = បុរសដែលមានកិត្តិនាមល្បីល្បាញក្នុងលោក ។ និយម = កំណត់អនុលោមតាម ។ ឋានៈ (ឬ ឋានន្តរ) = មុខងារ, ថ្នាក់សក្តិយស ។

ពាក្យចោទសួរ .— នៅនាប្រទេសតើគេនិយមរាប់អានអ្វី ? ការអានសៀវភៅនាំមកនូវប្រយោជន៍អ្វីខ្លះ ? ទឹងអាន គេត្រូវរើសរកសៀវភៅយ៉ាងដូចម្ដេច ? ។

---

## មជ្ឈិមដ្ឋាន ទី ២

### កវីបណ្ឌិត

នៅលើពិភពលោកយើងនេះ ទោះនៅនាប្រទេសដែលប្រកបខាងគ្រាត្តសម្បត្តិយ៉ាងបរិបូណ៌ក៏ដោយ ក៏គង់គេប្រទះឃើញមានមនុស្សពប់

រយាប់ពាន់ដែលកើតឡើងៗហើយ ចាកចិត្តលោកទៅវិញក្នុងសេចក្ដីទុក្ខវេទនា ៗ គួរអាណិតផងពួកពលទាសកម្មករក្រីក្រលំបាក ជាប់ពាក់នឹងដីស្រែ ខំប្រឹងធ្វើការដើម្បីជាប្រយោជន៍ចំពោះអ្នកដទៃ គ្មានឈប់-ឈរឡើយ ហើយបានយល់ឃើញជាក់ស្ដែង នៅជិតខ្លួន កូនស្លាប់វិនាសដោយសេចក្ដីស្រេកឃ្លាននឹងជម្ងឺគ្រុនរាក ៗ គួរអាណិតផងស្ត្រី-កំសត់ទុគ៌តអនាថា គ្មានទីលំនៅជ្រកកោន ខំឱបក្រសោបកូននៅនាដើមទ្រូង ដែលមានភាពជ៏ស្គាំងស្គម ឯទារកស្រែកយំទាទឹកដោះ ដែលរីងហួតអស់ទៅហើយ ៗ មានជាតំបាញខ្លះ ដោយមិនដឹង ខំត្បាញសំពត់ស្នបសំរាប់ខ្លួន ៗ

ចំពោះសេចក្ដីទុក្ខវេទនាទាំងនេះ តើកវីបណ្ឌិតបានធ្វើអ្វីខ្លះ? សេចក្ដីទុក្ខព្រួយទាំងអម្បាលមាណអ្នកកវីក៏បានជួយឈឺចាប់ដែរ សេចក្ដីខ្សឹកខ្សួលដោយសំរាត់នឹងសេចក្ដីត្អូញត្អែរទាំងនេះ ដែលគេពុំអាច[illegible]បាន ក៏ចូលទៅក្នុងសំឡេងអ្នកកវី លាយឡំនឹងចំរៀង ហើយកាលណាចំរៀងនេះ ចាកចេញផុតអំពីដួងចិត្តទៅ ក៏អណ្ដែតទៅឆ្ងាយ គ្មានឈប់ឈរ ទៅតាមមាត់មនុស្សលោកនឹងតាមអាកាសវេហាស៍ ៗ

ពាក្យពន្យល់ .– កវីបណ្ឌិត = អ្នកប្រាជ្ញដែលចេះកាព្យឃ្លោង

ទាសកម្មករ= ពួកខ្ញុំកំដរនឹងអ្នកធ្វើការស៊ីឈ្នួល

អភិជន= ជន ១ ពួកក្នុងសម័យបុរាណដែលមានភាពប្រហែលគ្នា

នឹងមេកន្ទ្រាញ ។

ទារក = ក្មេងតូច ។

ពាក្យចោទសួរ.– ក្នុងពិភពលោកយើងនេះ តើគេប្រទះឃើញសេចក្តីទុក្ខវេទនាអ្វីខ្លះ? ចំពោះសេចក្តីទុក្ខវេទនាទាំងនេះ តើអ្នកគិតធ្វើអ្វី? ដោយរបៀបយ៉ាងណា? ។

---

# មជ្ឈិមដ្ឋានទី ១

## រៀនមើល – សរសេរតាមសូត្រ

ទន្សាយជាប់អន្ទាក់ (រឿងសំរាំងទំព័រ ៣៧) ។

ពន្យល់ពាក្យ.– ទន្សាយ= ឈ្មោះសត្វតូចៈជើង ៤ មិនផឹកទឹក ផឹកតែសន្សើម, ជាសត្វផ្លាងពីបាកផ្សាំង ។ សំណាប= ស្រូវទើបដុះ-ក្នុងថ្នាល ។ អន្ទាក់= ចំណងរូតឯង សំរាប់ទាក់សត្វ ។ គន្លង= ផ្លូវ-

ស្នាម, ជ្រលង, ដាន, គន្លងនង្គ័ល, ដើរតាមគន្លង, គន្លងមង, គន្លងលប, គន្លងត្រី ។ អង្វរ= ល្បួងលោមឲ្យគេអាណិត ពោល= រត់-ពោះដើងទាំង ៤ ពេញទំហឹង, ទន្សាយពោល ។ ផាប់= ស្ទាប, គាំង: និយាយបំពោះតែអនុបាទិន្នករូប មានឈើនឹងគ្រឿងបក្រជាដើម: ឈើ-ផាប់, ឫស្សីផាប់, នាឡិកាផាប់ ។ អាល័យ= ទីស្ថិត ។ អាល័យ-តែ= ចិត្តខ្ជាប់នឹង ។ ប្រាជ្ញា= វិធីចិត្តដែលយល់ច្រើន, យល់រហ័ស; ការយល់ជាក់ច្បាស់ ។ ស្ទុះ= ចាកចេញភ្លាម ។ បុរស= អ្នកបំពេញចិត្តស្រី, អ្នកបំពេញកិច្ចការក្នុងប្រទេសដែលខ្លួននៅ (មនុស្សប្រុស) ។ ម្នីម្នា= ប្រញាប់ប្រញាល់ ។ អង្រុត= គ្រឿងនេសាទុបករណ៍ ១ យ៉ាងសំរាប់ក្រុងត្រី ។ មុជ= ពន្លិចខ្លួនទៅក្នុងទឹក ។

ពាក្យសួរ.— ទន្សាយបំផ្លាញអ្វីរបស់មនុស្ស ? មនុស្សគិតដូចម្តេចនឹងចាប់ទន្សាយឲ្យបាន? ទន្សាយជាប់អន្ទាក់ហើយតែវាគិតដូចម្តេចនឹងដោះខ្លួនឲ្យរួច ? អ្នកយល់ឃើញថាទន្សាយជាសត្វដូចម្តេច ? ។

# វិធីបង្រៀន

## បង្រៀនពាក្យនិងភាសា

ពាក្យនិងភាសាគឺជាវិជ្ជាមួយយ៉ាងវិសេស ដែលបំបែកទៅវិជ្ជាឯទៀត ដូចជាវិជ្ជាបង្រៀនមើល – សរសេរតាមសូត្រ ។ល។

ឯនឹងបង្រៀនពាក្យ មុនដំបូងត្រូវបង្រៀនពាក្យណាដែលងាយ ៗ សិន រួចបំមបង្រៀនពាក្យពិបាកជាខាងក្រោយ ។

បើបង្រៀន នាម ត្រូវមានរបស់ដែលជា នាម មកបង្ហាញពន្យល់ បើគ្មានរបស់នោះទេ ត្រូវគូររូបបង្ហាញសិស្ស បើមានរូបស្រាប់ត្រូវចង្អុលបង្ហាញផង ។

បង្រៀន គុណនាម ត្រូវប្រៀបប្រដូចរបស់នោះឲ្យឃើញថា តូចឬធំ វែងឬខ្លី សឬខ្មៅ ល្អឬអាក្រក់ ។ល។

បង្រៀន កិរិយាសព្ទ គឺត្រូវឲ្យសិស្សធ្វើទំនងតាមកិរិយារបស់នោះគឺដូចជាបង្គាប់សិស្សឲ្យក្រោក ឲ្យដើរ ឲ្យឈរ ឲ្យដូត ឲ្យចិត ៗ

# អាទិត្យទី ១.– បង្រៀនពាក្យ

## ១– អំពីសាលារៀន

នាម .– សាលារៀន ឆ្នាំសិក្សា ពេលចូលរៀន ពេលសំរាក សាលាសិក្សាវត្ត សាលាបឋមវិជ្ជានៅភូមិ សាលាបំពេញវិជ្ជា សាលាឧត្តម-វិជ្ជា សញ្ញាប័ត្រ ។

គុណនាម .– ថ្មី ចាស់ ល្អ អាក្រក់ ខ្ពស់ ទាប យូរ ឆាប់ ជិត ឆ្ងាយ ខ្ជិល ឧស្សាហ៍ ។

កិរិយាសព្ទ .– សុំចុះឈ្មោះ ចូលរៀន រៀនបំពេញវិជ្ជា ឈប់សំរាក ឈប់រៀន ឡើងថ្នាក់ ប្រឡង បានសញ្ញាប័ត្រ ។

ហាត់ភាសា .– ក្នុងមួយឆ្នាំសិក្សា សិស្សរៀនប៉ុន្មានខែ ? ឈប់សំរាកប៉ុន្មានខែ ? នៅពេលណាដែលសិស្សចូលរៀនជាថ្មី ? សាលាដែលអ្នករៀនឈ្មោះសាលាអ្វី ? (សាលាសិក្សាវត្តឬសាលាបឋមវិជ្ជានៅភូមិ ។ ល ។ ) សិស្សត្រូវធ្វើដូចម្តេចដើម្បីឲ្យបានឡើងថ្នាក់ ? ឲ្យបានប្រឡងជាប់លេខ ? សិស្សកំជិល បានសម្រេចប្រយោជន៍អ្វីដែរឬទេ ? ។

**វិធីហាត់សរសេរ** .– ឲ្យតែងសេចក្ដីជាឃ្លា ៗ ឬឲ្យបំពេញសេចក្ដីនៅកន្លែងចន្លោះពងត្រី ដូចខាងក្រោមនេះ ៖

ក្នុងមួយឆ្នាំសិក្សា .... ( សិស្ស ) មករៀន ( ៩ ខែ ) ឈប់សំរាក .... ( ៣ ខែ ) ។ ខ្ញុំរៀននៅសាលា .... ( សិក្សាវត្ដ ឬសាលាបឋមវិជ្ជានៅភូមិ ។ល។ ) ។ ខ្ញុំត្រូវ .... ( ខំស្វាហាប់រៀនសូត្រ ) ដើម្បីឲ្យបានឡើងថ្នាក់ ឬប្រឡងជាប់នៅ ..... ( ពេលដាច់ឆ្នាំ ) ។

## ២ .– សិស្សឧស្សាហ៍រៀនសូត្រ

សៀវភៅវិជ្ជាខេមរភាសាបរិច្ចណាដ្ឋាន ទំព័រ ២៥ មេរៀនទី ១៧។ សុំកែពាក្យខ្លះក្នុងមេរៀននេះ ដូចជា គឹត = ត្រូវសរសេរជាគិត មឹន = ជាមិន ។ ត្រិម = ជាត្រឹម ។

សុំរើសពាក្យ នាម – គុណនាម – កិរិយាសព្ទ ដាក់ឲ្យសិស្សរៀនផង ។

**ហាត់ភាសា** .– អ្នកត្រូវធ្វើដូចម្ដេចដើម្បីឲ្យបានចេះដឹង ? អ្នកស្រឡាញ់ចំណេះវិជ្ជាឬទេ ? ព្រោះអ្វី ? មនុស្សចេះដឹងយ៉ាងដូចម្ដេច ?

ចុះមនុស្សល្ងង់ខ្លៅយ៉ាងណាវិញ ? ដល់អ្នកធំឡើងអ្នកចង់ធ្វើអ្វី ? ( ចង់ធ្វើនាម៉ឺន ឬចង់រកស៊ី ) ។ ហេតុអ្វី ? ។

បើមេរៀននេះមិនគ្រប់គ្រាន់ សូមជ្រើសរើសសេចក្ដីឯទៀតយកមកបង្រៀនពាក្យ – ហាត់ភាសា – ហាត់សរសេរថែមទៀត តែសេចក្ដីនោះឲ្យប្រារព្ធទៅលើ “ សាលារៀន, សិស្ស, ប្រដាប់ ប្រដាប់របស់សិស្ស ” តាមកំណត់ចែកវិជ្ជាបង្រៀនក្នុងខែទី ១ ។

## បង្រៀនមើល

១ – ពីព្រោះអ្វីបានជាខ្ញុំទៅសាលារៀន

សៀវភៅវិជ្ជាខេមរភាសាបរិច្ចណដ្ឋានទំព័រ៤ មេរៀនទី៣ ។

ពន្យល់ពាក្យ. – មិត្តសំឡាញ់ – ពត៌មាន – ផលព្រះធរណី – ខ្នាន – លុះដោយគន្ធិធម៌ ។

២ – សេចក្ដីព្យាយាមនឹងបានសម្រេចដូចប្រាថ្នា ។

សៀវភៅវិជ្ជាខេមរភាសាអាទិកដ្ឋាន ៨២ មេរៀនទី ៥៥ ។

ពន្យល់ពាក្យ. – សញ្ញាប័ត្រឧត្ដមវិជ្ជា – សាលាបឋមវិជ្ជាបារាំងខ្មែរ – ដុតបំភ្លឺរៀន – សេចក្ដីព្យាយាម ។

## របៀបបង្រៀនមើល

ឲ្យបម្លងសូត្រនេះនៅក្ដារខៀនបញ្ឈរ ដោយអក្សរផ្ចិតផ្ចង់ បើជាសិស្សគ្មានសៀវភៅគ្រប់គ្រាន់ទេ ។

គ្រូត្រូវមើលសូត្រនេះមុនឲ្យសិស្សស្ដាប់ ថាមួយៗ ឲ្យច្បាស់ពាក្យ ឬតួអក្សរនោះ ។

គ្រូមើលសូត្រនេះឲ្យសិស្សមើលតាមពីរឬបីនាក់ម្ដង ឬឲ្យថាតាមព្រមគ្នាទាំងអស់ក៏បាន រួចបង្គាប់ឲ្យសិស្សម្នាក់មើល ឲ្យថាខ្យល់អក្សរឲ្យត្រឹមត្រូវ ។

ពន្យល់ពាក្យពិបាកដែលមាននៅក្នុងសូត្រ ។

ហៅសិស្សផ្លាស់គ្នាឲ្យមើលសូត្រនេះកុំហៅសិស្សរៀងគ្នាតាមតុ ។ គ្រូបង្គាប់ឲ្យកែពាក្យសំដីណាដែលសិស្សអានថាមិនច្បាស់ ។

## សរសេរតាមសូត្រ

សូមលោកគ្រូជ្រើសរើសសេចក្ដីណា ដែលបានបង្រៀន ក្នុងវិធី

បង្រៀនពាក្យ - ហាត់ភាសា - បង្រៀនមើល យកមកបង្រៀនដាក់អក្សរត្រឹមត្រូវផងចុះ តែមិនត្រូវយកពាក្យពិបាកណាមួយដែលសិស្សមិនទាន់បានឃើញ បានស្គាល់ មកឲ្យសរសេរតាមគ្រូថានោះទេ ។

## អំពីបង្រៀនដាក់អក្សរត្រឹមត្រូវតាមគ្រូថា

មុនដំបូងត្រូវមើលសូត្រឲ្យសិស្សស្តាប់ រួចសរសេរពាក្យពិបាកជាចំណាំនៅក្តារខៀន ហើយពន្យល់ពាក្យនោះផង ។

ឲ្យសិស្សសរសេរពាក្យនោះនៅលើក្តារខៀនជាច្រើនដង ហើយឲ្យមើលប្រកបថាពាក្យនោះ រួចហើយលុបចេញ ។

ត្រូវលុបពាក្យដែលសរសេរនៅក្តារខៀនចោលចេញ ធ្វើបែបនេះដើម្បីឲ្យសិស្សឃើញពាក្យនោះត្រឹមត្រូវ ៖

ក ) – ឲ្យសិស្សចំណាំដោយភ្នែកបានឃើញ ។

ខ ) – ឲ្យសិស្សសរសេរពាក្យនោះច្រើនដង ដើម្បីឲ្យចំណាំដោយដៃបានគូស - បានសរសេរ ។

ហៅសូត្រឲ្យសិស្សសរសេរតាម ថាឲ្យមួយ ៗ ហើយច្បាស់លាស់ផង គ្រូដើរក្រោយខ្នងសិស្ស ដើម្បីសំគាល់មើលថា សិស្សនេះសរសេរខុសច្រើន សិស្សនោះសរសេរត្រូវច្រើន ។

គ្រូសរសេរកែសូត្រនេះនៅក្ដារខៀនម្ដងមួយឃ្លា ៗ ឲ្យសិស្សកែសៀវភៅវាតាម ពាក្យណាដែលវាសរសេរខុស ឲ្យវាគូសខ្មៅដៃពីក្រោម ឲ្យសរសេរពាក្យត្រូវពីលើពាក្យខុស ហើយដាក់ចំនួនខុសប៉ុន្មាន ៗ ផង

គ្រូត្រូវមើលដាក់ពិន្ទុឲ្យសិស្សផង ។

ឲ្យសិស្សសរសេរពាក្យដែលខុស (ខុសមួយមាត់ឲ្យសរសេរមួយបន្ទាត់) ។

## អក្សរផ្ចង់

យើងត្រូវជ្រើសរើសតួអក្សរដែលមានសណ្ឋានប្រហែល ៗ គ្នា មកដាក់ឲ្យសិស្សហាត់សរសេរ ដូចខាងក្រោមនេះ ៖

ក ភ គ ត ឥ ឡ

ក កា កឹ កូ កួ កើ កៀ កែ កោ កៅ កុ កំ កាំ

កុំកោកកាក កើតក្ដីក្ដាំ ភិតភ័យ កុំភូតភរគេ

(ឲ្យសរសេរអក្សរធំ ១ បន្ទាត់ កណ្ដាល ១ បន្ទាត់ តូច ១ បន្ទាត់)

សូមធ្វើឲ្យស្ទួគ្រប់តាមរបៀបបង្រៀនអក្សរផ្ចង់ ។

## តែងសេចក្ដី

### អំពីសាលារៀន

ចូរឆ្លើយតាមពាក្យចោទខាងក្រោមនេះ ៖

១ - សាលារៀនអ្នកនៅទីកន្លែងណា? ២- នៅជុំវិញសាលានោះមានអ្វីខ្លះ? ៣ - សាលានោះសង់ពីអ្វី? ៤ - មានប៉ុន្មានថ្នាក់? ៥ - អ្នករៀននៅថ្នាក់ណា? ៦ - មានគ្រូប៉ុន្មាន? សិស្សប៉ុន្មាននាក់? ៧ - នៅក្នុងសាលាមានតុតាំងអ្វីខ្លះ? ៨ - អ្នកស្រឡាញ់សាលានោះឬទេ? ៩ - ព្រោះអ្វី? ។

---

## កុមារដ្ឋាន

### អាទិត្យទី១. – រៀនពាក្យនិងភាសា: វត្ថុនៅក្នុងកន្លែងរៀន

ដីស - ក្ដារខ្មៀន - ខ្មៅដៃ - ដងប៉ាកកា - ទឹកខ្មៅ ។ ដីសស - ក្ដារខ្មៀនខ្មៅ - ខ្មៅដៃស្រួច - ដងប៉ាកកាមូល ។ សរសេរអក្សរ, លុបក្ដារ - ចិតខ្មៅដៃ ។

ដំបូន្មាន .– ដើម្បីនឹងបង្រៀនពាក្យត្រូវឲ្យមានរបស់ប្រមូលទុកស្រេចនៅចំពោះមុខសិស្ស ទើបចង្អុលប្រាប់ ឬឲ្យក្មេងរកបង្ហាញរបស់

ដែលត្រូវបង្រៀន ។ ពាក្យដែលត្រូវរៀននោះមិនបាច់ឲ្យក្មេងស្គាល់ថានាម , គុណនាម , កិរិយាឡើយ ។ វិធីបង្ហាត់ភាសាត្រូវយកតែពាក្យដែលក្មេងបានរៀនហើយ ដូចរបៀបដែលយើងធ្វើនេះជាគំរូ ពាក្យចោទឬពាក្យឆ្លើយត្រូវឲ្យថាពេញប្រយោគ គឺត្រូវនិយាយតាមរបៀបវេយ្យាករណ៍ ។

គំរូ — អ្នកមានដីសឬទេ ? ដីសរបស់អ្នកមានសភាពដូចម្ដេច ? ក្ដារខៀននេះជារបស់អ្នកណា ? - អ្នកណាឬនរណាមានខ្មៅដៃ ? - មានដងប៉ាកកា ?

១ទៀតនឹងបង្រៀន ១ ពេល ៗ ត្រូវប្រើពាក្យ ៥, ៦ មាត់បានហើយ ។ ពាក្យដែលយើងឲ្យខាងក្រោយនេះត្រូវលែបង្រៀនឲ្យគ្រប់គ្រាន់ក្នុង ១ អាទិត្យ បើមិនគ្រាន់ត្រូវរកថែមទៀត ។ នៅថ្ងៃចុងអាទិត្យ គួរតែសាបង្រៀនពីដើមឡើងវិញ ។

ពាក្យរៀន — ក្ដារខៀន , កំណាត់សំពត់ , បន្ទាត់វែង , គំនូរ , ផែនទី , ផ្ទាំងគំនូរ , ផ្ទាំងច្បាប់អក្សរ ។ តារាងប្រក្រតិទិន - តារាងកំណត់ពេលរៀន - ផ្ទាំងរបៀបរៀនតាមខែ ។

ធំ, គគ្រាត, ក្រខ្វក់, វៃយ៉, ត្រង់, សំប៉ែត, ស្រស់, ល្អ, ខៀវ, ខ្មៅ, ក្រហម, បួនជ្រុង, ស្មើ, ច្បាស់, ស្រអាប់ ។

ព្យួរ, បញ្ឈូរ, ភ្ជាប់, លុប, សរសេរ, ចង្អុល, មើល, គួរ, គួស, លើកដាក់ ។

## រៀនមើល-សរសេរ

វិធីបង្រៀនមើល - សរសេរជាដម្បូងនៅថ្នាក់កុមារដ្ឋាន ទើបមានក្នុងឯណាពិតនោះឥតអង្គឹមាន សៀវភៅជាន់ចាស់ឲ្យបង្រៀន ក បំបែកជាមុន សៀវភៅជាន់ក្រោយឲ្យបង្រៀនស្រៈនិស្ស័យជាមុន ។ សេចក្ដីនេះវិធីរៀនដម្បូង យើងនឹកឲ្យគ្រូរើសរកបែបណាដែលគាប់ - ចិត្តបង្រៀនចុះ ប៉ុន្តែចំណែកខាងខ្ញុំ ៗ យល់ឃើញថាត្រូវឲ្យក្មេងរៀនអក្សរ អ ជាដម្បូង ។ ឲ្យសរសេរ អ ហើយថា អ ។ គូរផងថាផង ហើយត្រូវឲ្យថាពាក្យបណ្ដុះស្មារតី "ខ្ញុំអរ, ប៉ាយអ, ប៊ុអ, អក ។

ថ្ងៃទី ២ - អា - ពាក្យបណ្ដុះស្មារតី "អារឈើ, អាខេះ

ថ្ងៃទី ៣ - អិ អី អឹ អឺ - ពាក្យបណ្ដុះស្មារតី "អេកចាយ, អីអើ ។

ថ្ងៃទី ៤ - អុ អូ អួ ឲ្យរកពាក្យបណ្ដុះស្មារតី ។

ថ្ងៃទី ៥ - អ អា អិ អី អឹ អឺ អុ អូ អួ ។

ដំបូន្មាន - នៅថ្នាក់កុមារដ្ឋាន គ្រូត្រូវកុំបង្ខំក្មេងឲ្យបេះពិចារណាយល់ដឹងខ្លួនឯងពេក ត្រូវបង្ខំឲ្យក្មេងចាំដៃតែប៉ុណ្ណោះ ។

បើមានក្មេងខ្លះចេះសរសេរស្រាប់ហើយ ឲ្យក្មេងចេះស្រាប់នោះ នាំក្មេងដែលមកជាដំបូងសរសេរ, អាន ហើយគ្រូត្រួតត្រាមើលដូច្នេះក្មេងចេះស្រាប់នឹងក្មេងមិនទាន់ចេះធ្វើការដូចគ្នា ។

## អាទិត្យទី ២ .– រៀនពាក្យ ហាត់ភាសា

ពាក្យ — តុក្អូនសិស្ស - តុគ្រូ - ជើងម៉ា - កៅអី - ថតតុ - ជើងតុ - ទូ - កញ្ចក់ទូ - អំបោស - ចង្កៀង - ធ្នឹម ។

វែង - រលោង , រលីប - រៀប - ត្រង់ - ចាស់ - រលុង - ផុយ - ក្លឹ - រេប - ខូប ។ ហូត - ដក - រៀប - ដូត - ដុស - សំអាត - បោស - ប្រយ័ត្ន - ទុក ។

### រៀនមើល សរសេរ

អេ , អើ , អឿ , អៀ , អែ , អៃ , អៅ , អោ , អាំ , អុំ , អះ , អំ

## អាទិត្យទី ៣ .– រៀនពាក្យ ហាត់ភាសា

ពាក្យ·– សៀវភៅសរសេរ , សៀវភៅមើល , សៀវភៅនព្វន្ត, សៀវភៅវត្ថុស្វាធ្យាយន៍ , សៀវភៅភូមិសាស្ត្រ , វចនានុក្រម , សៀវភៅ

កម្ពុជាវិតារ, ក្រដាស, ក្រដាសផ្ដិត, ជ័រលុប, បន្ទាត់, ស្លាបប៉ាកកា, ក្របសៀវភៅ ។

ស្ដើង, ក្រាស់, ថ្មី, ចាស់, ទក់, រហែក, ទន់, រឹង, ក្ដិចខ្ទុះ, ដាម, ស្រួច, រឹល ។

ដាក់ក្រប, អានពាក្យ, ទន្ទេញ, បើកសៀវភៅ, គូសបន្ទាត់, លុប, ជុស, សូត្រ, ស្នាដព្រាយ, ផ្ដិតទឹកខ្មៅ ។

## រៀនមើល សរសេរ

អាទិត្យនេះត្រូវបង្រៀននៅថ្ងៃដំបូងអក្សរ ក ។ ពាក្យបណ្ដុះស្មារតី
" កកុក, កដប, កករទឹក, ទឹកកក, កដៃ, កជើង ។

ថ្ងៃទី ២ .— ផ្សំលំដាប់តទៅ = កា — កិ កី កឹ កឺ — កុ កូ កួ — កើ កេ កឿ កៀ កែ កៃ កោ កៅ — កុំ កំ កាំ កះ ។ — រៀនប្រកប = កក, កុក, កែក, កាក, កោក, កេក, កុះ, កោះ ។

---

# បរិទ្ធណាដ្ឋាន

## រៀនពាក្យ — ហាត់ភាសា

អាទិត្យទី ១ និងទី ២.— សូមបង្រៀនសាពីពាក្យដែលបាន

រៀនទាំងអម្បាល់ម៉ាននៅកុមារដ្ឋានក្នុងខែកញ្ញានេះ ។

## រៀនមើល

១- កូនសិស្សឧស្សាហ៍រៀនសូត្រ (សៀវភៅបរិច្ឆណដ្ឋាន ទំព័រ ២៥ ) ។

២- កូនសិស្សខ្ជិល (សៀវភៅដដែលទំព័រ ២៦ ) ។

៣- ត្រូវតែរៀនដំរិះវិជ្ជា (សៀវភៅដដែលទំព័រ ៦១) ។

សុំឲ្យកែពាក្យខុស= សូត្តជាសូត្រ; គឹតជាគិត ; មឹនជាមិន; ត្រិម-ជាត្រឹម ( ទំព័រ ២៥ ); ខ្ជឹលជាខ្ជិល ; កិរិយ៉ាជាកិរិយា (ទំព័រ២៦) ។

## សរសេរតាមសូត្រ

១- កូនសិស្សឧស្សាហ៍រៀនសូត្រ (សៀវភៅដដែលទំព័រ ២៥) ។

២- កូនសិស្សខ្ជិល (សៀវភៅដដែលទំព័រ ២៦ ដល់រឿយៗ) ។

៣- កូនសិស្សខ្ជិល (ត) ដល់ចប់ ។

## រៀនពាក្យហាត់ភាសា

អាទិត្យទី ៣.– សុំសាបង្រៀនពាក្យដែលរៀនរួចហើយនៅថ្នាក់កុមារដ្ឋានខែងដែល

## រៀនមើល

១- ដម្រីកមរមាស់ (សៀវភៅដែលទំព័រ ២២ ទៅ ២៣) ។

២- ដម្រីកមរមាស់ (ត) (សៀវភៅដែលទំព័រ ២៤-២៥) ។

៣- ត្រូវថែទាំសំលៀកបំពាក់ (សៀវភៅដែលទំព័រ ៧៦) ។

## រៀនពាក្យ ហាត់ភាសា

អាទិត្យទី ៤.– សុំសាបង្រៀនឡើងវិញពាក្យដែលបានរៀនពីអាទិត្យមុនៗមក ។

## រៀនមើល

សុំបង្រៀនសាឡើងវិញ រឿងមើលណាដែលលោកគ្រូយល់ថាក្មេងចេះពុំសូវពេញលេញ ។

## សរសេរតាមសូត្រ

១- ដម្រីកមរមាស់ (ដល់ពេញទាំងខ្លួន)- (ទំព័រ ២៣)

២- ដម្រីកមរមាស់ (ត) ដល់គួរឲ្យខ្ពើមណាស់ (ទំព័រ ២៤)

៣- រឿងដដែល-ពីកាលណាកើតកម....ដល់ចប់(ទំព័រ២៤)

---

# មជ្ឈិមដ្ឋានទី២ និង ឧត្តមដ្ឋាន

## នព្វន្ត

### អាទិត្យទី ១.– អំពីរៀនរាប់និងមើលចំនួន

គេត្រូវរាប់និងមើលចំនួនលេខដប់តួដំបូងថា៖

| | | | |
|---|---|---|---|
| មួយ ... | ១ | ប្រាំមួយ | ...៦ |
| ពីរ ... | ២ | ប្រាំពីរ | ...៧ |
| បី ... | ៣ | ប្រាំបី | ...៨ |
| បួន ... | ៤ | ប្រាំបួន | ...៩ |
| ប្រាំ .. | ៥ | សូន្យ (គ្មាន) | ០ |

១ ដប់ដងត្រូវជាដប់ (១០) គេសរសេរលេខ១ ហើយថែមសូន្យមួយខាងស្តាំ ។

ដប់ ។ ដងត្រូវជាមួយរយ (១០០) ។

ពីដប់ទៅ ១០០ គេត្រូវរាប់ថា:

| | | | |
|---|---|---|---|
| ដប់ ... | ១០ | ហុកសិប | ... ៦០ |
| ម្ភៃ ... | ២០ | ចិតសិប | ... ៧០ |
| សាមសិប ... | ៣០ | ប៉ែតសិប | ... ៨០ |
| សែសិប ... | ៤០ | កៅសិប | ... ៩០ |
| ហាសិប ... | ៥០ | មួយរយ | ... ១០០ |

ដើម្បីនឹងរាប់ចំនួនពីដប់ដល់ ១០០ គេត្រូវថែមចំនួនរាយតាំង ៩ ទៅលើខ្ទង់ដប់ ។

គេរាប់ថា ដប់មួយ ១១ ឬមួយតណ្តប់

ដប់ពីរ ១២ ឬ ពីរតណ្តប់

ដប់ប្រាំបួន ១៩ ឬ ប្រាំបួនតណ្តប់

ម្ភៃមួយ ២១

កៅសិបប្រាំបួន ៩៩ (ល) ។

ឯចំនួនពី១០០ដល់ ១.០០០ គេត្រូវថែមចំនួនពី១ដល់៩៩ទៅលើ

ចំនួនរយគឺ មួយរយមួយ....... ១០១

មួយរយប្រាំពីរ....... ១០៧

ពីររយកៅសិបប្រាំបួន.... ២៩៩

ប្រាំរយប៉ែតសិបប្រាំបី... ៥៨៨

ប្រាំបួនរយកៅសិបប្រាំបួន... ៩៩៩ (ល) ។

រៀនសរសេរចំនួន ៖- ពី១០ដល់១០០ ។

ត្រូវដាក់ខ្ទង់ដប់មុនរួចដាក់ខ្ទង់រាយមកខាងស្តាំទៀត

ដប់ប្រាំ...១៥ ចិតសិបបួន...៧៤

សាមសិបប្រាំពីរ ៣៧ ប៉ែតសិបពីរ..៨២

ហាសិបបី. ៥៣ កៅសិបប្រាំបួន ៩៩ ។

ឯចំនួនពី ១.០០០ ត្រូវសរសេរខ្ទង់រយមុនរួចចុះចំនួនខ្ទង់ដប់ - ខ្ទង់រាយតៗមកខាងស្តាំទៀត ឯខ្ទង់ណាគ្មានលេខគេដាក់សូន្យជំនួស ។

មួយរយសាមសិបប្រាំពីរ ១៣៧

ពីររយប្រាំបី ២០៨

ប្រាំមួយរយ ៦០០

ប្រាំបីរយកៅសិបប្រាំបួន ៨៩៩ (ល) ។

**អំពីលេខបូក** .— ឧបមា ខ្ញុំមានគោមួយហ្វូង បើខ្ញុំចង់ដឹងចំនួនគោរបស់ខ្ញុំតើប៉ុន្មាន នោះខ្ញុំត្រូវរាប់គោក្នុងហ្វូងនោះទាំងអស់ ខ្ញុំឃើញគោ ២៤ ។

បើខ្ញុំមានគោមួយហ្វូងទៀត ខ្ញុំក៏ត្រូវរាប់ដូចខាងលើនេះដែរ ខ្ញុំឃើញមានចំនួនគោ ៣៥ ។

ឥឡូវនេះ បើខ្ញុំចង់ដឹងចំនួនគោដែលខ្ញុំមានទាំង ២ ហ្វូងនោះ ខ្ញុំមិនចាំបាច់នាំគោទាំងពីរហ្វូងនោះមកបញ្ចូលគ្នា ហើយរាប់សាជាថ្មីទៀតនោះទេ ខ្ញុំគ្រាន់តែធ្វើលេខបូកក៏អាចឃើញចំនួនទាំងអស់ហើយ គឺយកចំនួនគោ ២៤ក្នុងហ្វូងទី ១ មករួមជាមួយនឹងចំនួនគោ ៣៥ ក្នុងហ្វូងទី ២ ។

ទឹងបូកចំនួនគេសរសេរដូច្នេះ៖

គោ ២៤ + គោ ៣៥ = ៥៩ គោ

ទឹងធ្វើលេខបូកគេត្រូវតាំងចំនួន មួយលើមួយក្រោម ត ៗ គ្នា ហើយដាក់លេខឲ្យចំខ្ទង់ គឺខ្ទង់រាយក្រោមខ្ទង់រាយ ខ្ទង់ដប់ក្រោមខ្ទង់ដប់ ខ្ទង់រយក្រោមខ្ទង់រយដូចខាងក្រោមនេះ៖

```
   ២៤
+  ៣៥
 ─────
   ៥៩
```

ការហាត់ .– សុំឲ្យសិស្សធ្វើលេខឲ្យបានច្រើននៅក្ដារខៀន

១២៦ + ៣១៥ + ២០៧ = ... ។ ៦៣៨ + ២៤៦ + ៣១៤ = ... ។ ២៥១ + ៧៦ + ៣២៩ + ២១ = ... ។ល។

បំណោទ .– អង្ករ ៣ បាវ បាវទី ១ ទម្ងន់ ៩៨ គីឡូក្រាម បាវទី ២ ទម្ងន់ ៩៧ គីឡូ បាវទី ៣ ទម្ងន់ ១០៥ គីឡូ ឯបាវ ៥ ទៀតក្នុងបាវនីមួយ ៗ ទម្ងន់ស្មើនឹងបាវទី ២ តើអង្ករទាំងអស់ទម្ងន់ប៉ុន្មាន ? ។

អាទិត្យទី ២.– មើលនឹករាប់ចំនួនលើសពី ១.០០០ ឡើងទៅ

មួយពាន់ដប់ដងត្រូវជាមួយម៉ឺន ១·០០០០

មួយម៉ឺន ១០ ដងត្រូវជាមួយសែន ១·០០០០០ ។ល។

និងចំនួនពី ១.០០០ ឡើងទៅ ត្រូវថែមលេខចំនួន ១ដល់៩៩៩ ទៅលើខ្ទង់ពាន់ឬម៉ឺន

| | | |
|---|---|---|
| ដូចជា | បួនពាន់មួយ - - - - | ៤០០១ |
| | បួនពាន់ពីរ - - - - | ៤០០២ |
| | ប្រាំបីពាន់សែសិបប្រាំ - - - | ៨០៤៥ |

ប្រាំពីរពាន់ប្រាំបួនរយកៅសិបប្រាំបួន ៧៩៩៩ ។ល។

ត្រូវសរសេរលេខខ្ទង់ពាន់ឬខ្ទង់ម៉ឺនមុន ទើបចុះខ្ទង់ពាន់ខ្ទង់រយ ខ្ទង់ដប់នឹងរាយតាមទៅខាងស្ដាំទៀត ។

ខ្ទង់ណាដែលគ្មានលេខត្រូវដាក់សូន្យ ជំនួស ។

៥៤០៧; ៦០០៣; ៤១៧០៥ ។ល។

វិធីគេខុសត្រូវលេខបូក - បើចង់ដឹងថាលេខបូកឯណាមួយ ខុសឬត្រូវគេត្រូវបូកសាជាថ្មីម្តងទៀត ពីក្រោមឡើងទៅលើវិញ ដូចខាងក្រោមនេះ៖

៨ ២ ៨

---

២ ៩ ៧

+ ៤ ៧ ៨

៥ ៣

---

៨ ២ ៨

ការហាត់គិតមាត់ទទេ — គុណលេខមានចំនួន២ខ្ទង់នឹង១១ៗ នឹងគុណលេខមានចំនួនតាំងពីរខ្ទង់នឹង១១ នោះខ្ញុំត្រូវបូកលេខក្នុងចំនួនតាំងនោះ បើឃើញមិនហួសពី៩ ទេ ខ្ញុំត្រូវចុះចំនួនដែលបូកបាននោះចំចន្លោះកណ្តាលលេខតាំង ដូចខាងក្រោមនេះ

ឧបមា ៣៥×១១=

ត្រូវគិតថាក្នុងចំនួន ៣៥ មានលេខ ៣ មួយ តួនឹងលេខ ៥ មួយតួ ៣ នឹង ៥ ត្រូវជា ៨ យក ៨ ទៅចុះចន្លោះកណ្តាល ៣៥ ទៅជា ៣៨៥ យ៉ាងនេះៗ

ម្យ៉ាងទៀតបើបូកទៅហើយឃើញលើសពី ៩ គេត្រូវចុះតែចំនួនរាយនៅចន្លោះចំនួនតាំងហើយយកលេខខ្ទង់ ១០ ទៅថែមលើខ្ទង់ដប់បែបខាងក្រោមនេះ ៖

៦៧ រៀល × ១១ = ៧៣៧ ព្រោះ ៦ នឹង ៧ ត្រូវជា ១៣ ។

ការហាត់ .— ចូរគិតលេខខាងក្រោមនេះ ៖

| | |
|---|---|
| ៣៦ × ១១ = | ៥៣ × ១១ = |
| ៧៥ × ១១ = | ៩១ × ១១ = |
| ៤២ × ១១ = | ៧៨ × ១១ = ។ល។ |

បំណោទ .— កាលបុរសម្នាក់សងបំណុលគេអស់ ៣៩៥៛៦០ នៅសល់ប្រាក់ចំនួនប្រហែលនឹងបំណុលដែលសងគេនោះថែម ៨៩៛៧០ ទៀត ។ តើបុរសនោះមានប្រាក់ទាំងអស់ប៉ុន្មាន ? ។

## រង្វាស់រង្វាល់

### អាទិត្យទី ១ .— អំពីម៉ែត្រ

ម៉ែត្រជាខ្នាតប្រធាននៃរង្វាស់ប្រវែង ។ ខ្នាតដែលធំជាងម៉ែត្រគឺដេកាម៉ែត្រ (ដា. ម) ប្រវែង ១០ ម៉ែត្រ ។ ហិកតូម៉ែត្រ (ហ. ម) ប្រវែង ១០០ ម៉ែត្រ ។ គីឡូម៉ែត្រ (គ. ម) ឬ ១.០០០ ម ។

ឲ្យសិស្សហាត់គិតមាត់ទទេ ប្តូរសព្ទមួយទៅមួយ ដូចជាឲ្យរកក្នុង ១៣៥ ហ.ម. មានប៉ុន្មានម៉ែត្រក្នុង ៩៨៣ម.មានប៉ុន្មានដេកាម៉ែត្រ ២៤៦៧ ម៉ែត្រមានប៉ុន្មានគីឡូម៉ែត្រ ។ល។

ឯខ្នាតដែលតូចជាងម៉ែត្រនោះគឺ ដេស៊ីម៉ែត្រ (ដ.ម.) សង្ទីម៉ែត្រ (.ស.ម.) មីលីម៉ែត្រ (ម.ម)

ការហាត់.– សុំលោកគ្រូរើសរកការហាត់ដាក់ឲ្យសិស្សធ្វើផងចុះ ។

អាទិត្យទី ២ .– អំពីខ្នាតដែលមានរូបជាប្រធាន ។

ទ្វេដេស៊ីម៉ែត្រ តូចជាងម៉ែត្រ ៥ ដង; ១ ម៉ែត្រ; កន្លះម៉ែត្រ ០ម៥០; កន្លះដេកាម៉ែត្រ ឬ ៥ ម៉ែត្រ; ១ ដេកាម៉ែត្រ ឬ ១០ម៉ែត្រ ។

សុំឲ្យគ្រូរករង្វាស់ទាំងនោះ មកបង្ហាញឲ្យមើល-ឲ្យប្រើវាស់វត្ថុផ្សេង ៗឲ្យស្គាល់ ។

## ធរណីមាណសាស្ត្រ

អាទិត្យទី១ .– អំពីបន្ទាត់ផ្សេង ៗ

ខ្ញុំយកអម្បោះមួយសរសៃទាញចុងដើមឲ្យតឹង ខ្ញុំបានជាបន្ទាត់មួយ

បែប ។ ខ្ញុំយកក្រដាសមួយសន្លឹកបត់ជា២ផ្នត់ៗក្រដាសនេះជាបន្ទាត់ ១ ដែរ ។ គំនូសទៅ ។ នៅលើសៀវភៅអ្នកក៏ជាបន្ទាត់ដែរ បន្ទាត់ទាំងនេះ មានទំហំតែមួយគឺប្រវែង ។

បន្ទាត់មានច្រើនយ៉ាងផ្សេង ៗ ពីគ្នា ៖

បន្ទាត់ត្រង់ បន្ទាត់កាច់ បន្ទាត់ផ្តេក បន្ទាត់ឆៀង បន្ទាត់ឈរ បន្ទាត់កោង បន្ទាត់ស្រប ។

**លក្ខណៈនៃបន្ទាត់** ៈ— បន្ទាត់សំយុងត្រង់ គឺជាបន្ទាត់ដែលរត់ត្រង់តាមខ្សែកូនប្រយោល ( កូនតឹង ) បន្ទាត់ឆៀងដែលទ្រេតទៅឆ្វេងឬទៅស្តាំ ។ បន្ទាត់ផ្តេក គឺជា បន្ទាត់ដែលរត់ត្រង់តាមផ្ទៃទឹក ។ បន្ទាត់២—៣ ឬច្រើនបន្លាយឆ្ងាយទៅហើយ មិនជួបគ្នាសោះស្មានដូចផ្លូវដែករថភ្លើង ឬ ចិញ្ចើមថ្នល់ឈ្មោះថាបន្ទាត់ស្រប ។

**ការហាត់** ៈ— ចូរឲ្យសិស្សគូសបន្ទាត់ដែលបានរៀនខាងលើនេះដាក់នៅក្តារខៀនរួចឲ្យគូសដាក់ក្នុងសៀវភៅ ។

# គណិតដ្ឋាន

## ឥត្ត១

## ចំនួនពី ១ ដល់ ១០០

**អាទិត្យដំបូង** .— ចំនួនពី ១ ដល់ ៥០

នឹងបង្រៀនចំនួនមួយៗត្រូវបញ្ជាក់ចំនួននោះ ឲ្យសិស្សឃើញច្បាស់លាស់នៅភ្នែក ដូច្នេះសូមយកវត្ថុជាចង្កឹះ ឲ្យសិស្សរាប់ដូចរបៀបខាងក្រោមនេះ ៖

ចង្កឹះ ២០ ថែមចង្កឹះ ១ ទៀតចូលមក ត្រូវជាចង្កឹះម្ភៃមួយ ហើយត្រូវសរសេរ ២១ នៅក្ដារខៀនបញ្ឈរ ទៅរហូតដល់ ៥០ ។

### ១ – ហាត់មើលចំនួន

ឲ្យសិស្សមើលចំនួនដែលគ្រូបានសរសេរ នៅក្ដារខៀន ២០–២៥–៣៧–៣៨–៤៥–៤៦–៤៩–៥០ ។

### ២– ហាត់រាប់ចំនួន

ឲ្យរាប់ថែម បី ៗ–បួន ៗ–ប្រាំ ៗ ពី ១ ដល់ ៥០ រួចរាប់សាចុះមក ៥០ វិញ ។

## ៣ – ហាត់សរសេរចំនួននៅក្ដារខៀន

ឲ្យសិស្សសរសេរលេខតាមសូត្រ ២៩-២៥- ៣៧-៥០-៤៨

៤៤-២៧-២៦-១៩-១០- ។ល។

## ៤ ហាត់គិតមាត់ទទេ

ក្នុងមួយមានដប់ប៉ុន្មានដង? មានដប់ប៉ុន្មាននិងរាយប៉ុន្មាន ក្នុង ៣៥

៣៩-៤៦-២៧-៣៧-២៦-៤៥-២៩- ។ល។

ស្រូវ ១៥ តៅ ថែមស្រូវ ៨ តៅទៀត ត្រូវជាស្រូវប៉ុន្មានតៅ?

ខ្ញុំមានប្រាក់ ២៥ រៀល ឪពុកខ្ញុំឲ្យ ១៣ រៀលទៀត តើខ្ញុំមានប្រាក់ទាំងអស់ប៉ុន្មាន? ។

## ការហាត់

### ១– ឲ្យសរសេរជាលេខ

ដប់ប្រាំបួន ។ សាមសិបពីរ ។ សាមសិបប្រាំបួន ។ សែសិបប្រាំពីរ ។ ហាសិប

### ២ – បំណោទ

គ្រូខ្ញុំគាត់ទិញកៅអីមួយថ្លៃ ៣៥ រៀល គាត់លក់ទៅវិញបាន ចំណេញ ១៤ រៀល តើគ្រូខ្ញុំលក់កៅអីនោះប៉ុន្មានរៀល? ។

ខ្ញុំមាន ៤៣ រៀល ម្ដាយខ្ញុំគាត់ឲ្យមកទៀត ៧ រៀល តើខ្ញុំមានប៉ុន្មានរៀល?

អាទិត្យបន្ទាប់ ៈ– ចំនួនពី ៥១ ដល់ ១០០.

ការហាត់មើលចំនួន – ហាត់រាប់ចំនួន – ហាត់សរសេរនឹងការផ្ទួន សូមគ្រូមើលមេរៀនរបៀបអាទិត្យដម្បូង ។

## ហាត់គិតមាត់ទទេ

ត្រូវថែមប៉ុន្មានទៅ ៣៥ ទើបឲ្យបាន ៥០ ? ទៅ ២៥ ឲ្យបាន ៥៩ ? ទៅ ៣៧ ឲ្យបាន ៥៦ ? ទៅ ៣៧ ឲ្យបាន ៥៧ ? ទៅ ៧០ ឲ្យបាន ៩៩ ? ។

ព្រលឹមឡើង ឪពុកចែកលុយឲ្យកូន ៣ នាក់ កូនទី ១ បាន ១៥ កាក់ កូនទី ២ បានលើសកូនទី ១ បីកាក់ កូនទី ៣ បាន ២៥ កាក់ តើឪពុកនោះមានប្រាក់ ប៉ុន្មានកាក់ចែកឲ្យកូន ? ។

## ការហាត់

បំណោទ ៈ– ឈ្មួញម្នាក់លក់ទំនិញបាន ៥៩រៀល ហើយចំណេញបាន ២៩ រៀល តើថ្លៃដើមទំនិញនោះប៉ុន្មាន? ។

អ្នកស្រែម្នាក់ទិញស្រូវម្ដងបាន ២០ បាវ ម្ដងទៀតបាន ៣៥ បាវ ម្ដងទៀតបាន ៥៥ បាវ តើអ្នកស្រែនោះទិញបានស្រូវទាំងអស់ប៉ុន្មានបាវ? ។

# មជ្ឈិមដ្ឋាន

## នព្វន្ត

### ចំនួនពី ១ ដល់ មួយរយ

ករណីយកិច្ច ដែលមានដាក់តាំងប៉ុន្មាននោះ មិនអស់តែប៉ុណ្ណោះទេ គឺគ្រាន់តែដាក់ជាគំរូជាដំរាប់ដូច្នេះ សូមគ្រូជ្រើសរើសរកបន្ថែមទៀតដោយនៅផ្ចិតផ្ចង់ តាមវិធីគួរនាំឲ្យចំរើនរៀនទៅផង ។

នឹងបង្រៀនចំនួននីមួយ ៗ ត្រូវបញ្ជាក់ចំនួននោះ ឲ្យសិស្សឃើញច្បាស់លាស់ គឺត្រូវប្រើបង្គឹះ ហេតុនេះសូមរកប្រអប់ក្រដាស៣ ហើយបិទនៅមុខប្រអប់នោះថា ខ្ទង់រយ – ដប់ – រាយ ឧបមាដូចយើងរៀនលេខ ៣៩ សិស្សត្រូវយកបង្គឹះ ៣ ដាក់ក្នុងប្រអប់ខ្ទង់ដប់ ហើយយកបង្គឹះ ៩ ដាក់ក្នុងប្រអប់រាយ ហើយប្រាប់សិស្សថា ៣៩ មាន ដប់ ៣ ដងនឹងរាយ ៩ ។

### ១– ហាត់មើលចំនួន

ចូរឲ្យសិស្សមើលចំនួនខាងក្រោមនេះ ៖ ២៩ - ៣៧ - ៤៣ - ៤៦

៥០ - ៥៧ - ៥៦ - ៦០ - ៦៥ - ៦៨ - ៧៩ - ៣៦ - ៨៣ - ៨១ - ៩៧ ៩៩ - ៩២ ។ល។ .

## ២. – ហាត់រាប់ចំនួន

សូមឲ្យសិស្សរាប់ឡើងចុះចំនួនពី ១ ដល់ ៦០ – ពី ៦០ ទៅ ១០០ ម្ដងពីរ ៗ បី ៗ បួន ៗ ប្រាំ ៗ ឲ្យបានច្រើនគ្នា ហើយសាចុះមកវិញ ៗ

## ៣. – ហាត់សរសេរចំនួនក្នុងការធ្វន

ចូរសរសេរលេខ ២៧ - ៣៥ - ៤៥ - ៤៨ - ៥១ - ៥៨ ៥៩ - ៦១ - ៦៥ - ៦៩ - ៨០ - ៨៤ - ៤៥ - ៨៣ - ៨៧ - ៩៥ - ៩៩ ១០០ ។ល។

## ៤. – ហាត់គិតមាត់ទទេ

ត្រូវជាប៉ុន្មាន ៦៨ នឹង ១៦ ? ៧៣ នឹង ១៧ ? ៩២ នឹង ៧ ? នៅសល់ប៉ុន្មាន ៧៨ ដក ១១ ចេញ ? ៦៩ ដក ២៥ ចេញ ? ដក ១១ ចេញ ? – ត្រូវបន្ថែមប៉ុន្មានទៅ ៥០ ឲ្យបាន ៩០ ? ទៅ ៧៧ ឲ្យបាន ១០០ ? ទៅ ៣៩ ឲ្យបាន ៨៨ ? ទៅ ៦៦ ឲ្យបាន ៨៨ ? ទៅ ៥៥ ឲ្យបាន ៩៩ ? ត្រូវដកប៉ុន្មានពី ៨៩ ឲ្យនៅសល់ ៤០ ? ពី ១០០ ឲ្យ

នៅសល់ ៨០ ? ខ្ញុំអាយុ ២៥ ឆ្នាំ ឪពុកខ្ញុំអាយុលើសខ្ញុំ ៣៣ ឆ្នាំ តើឪពុកខ្ញុំអាយុប៉ុន្មាន ? ។

## ការហាត់

បំណោទ .– កូនសិស្ស ៣ នាក់មានគ្រាប់ឃ្លី ៨៥ កូនសិស្សទី ១ មានគ្រាប់ឃ្លី ២៥ កូនសិស្សទី ២ មានលើសកូនសិស្សទី ១ គ្រាប់ឃ្លី ១៥ តើកូនសិស្សទី ៣ មានគ្រាប់ឃ្លីប៉ុន្មាន ? ។

អ្នកស្រែម្នាក់មានសត្វមួយហ្វូង គឺគោ ៣៨ នឹងពពែ៥៣ អ្នកនោះលក់អស់គោ ១៥ នឹងពពែ ១៩ តើអ្នកស្រែនោះនៅសល់សត្វប៉ុន្មាន? ។

# វាចិកដ្ឋាន

## រង្វាស់–រង្វាល់

អាទិត្យដំបូង .– អំពីម៉ែត្រ

ម៉ែត្រជារង្វាស់សំរាប់វាស់ប្រវែង បណ្តោយ ទទឹង កំពស់ ។បមាដូចជាសំពត់ប្រវែងបណ្តោយ៦ម៉ែត្រ ផ្លូវទទឹង៤ម៉ែត្រ ជញ្ជាំងកំពស់២ម៉ែត្រ ។

ម៉ែត្រគេសរសេរកាត់យ៉ាងដូច្នេះ “ ម ” ដូចជា ៦ ម៉ែត្រគេសរសេរ ៦ម. ។ ៤ ម៉ែត្រ គេសរសេរ ៤ម. ។ល។

ម៉ែត្រមានច្រើនយ៉ាង មានម៉ែត្រឈើបន្ទាត់ ម៉ែត្រឈើបត់ ម៉ែត្រដែកឬស្ពាន់បត់ ម៉ែត្រសំពត់ ប៉ុន្តែម៉ែត្រសុទ្ធតែប្រវែងស្មើគ្នាទាំងអស់ ។

អ្នកលក់សំពត់ប្រើម៉ែត្របន្ទាត់ ។ ជាងធ្វើតុតាំងប្រើម៉ែត្របត់ឈើ ។ ជាងកាត់សំលៀកបំពាក់ប្រើម៉ែត្រសំពត់ ។ ជាងដែកប្រើម៉ែត្រស្ពាន់ឬដែក ។

## ១.– ហាត់គិតមាត់ទទេ –

**ម៉ែត្រសំរាប់ធ្វើអ្វី .–** ម៉ែត្រមានប៉ុន្មានយ៉ាង ? ម៉ែត្រអ្វីខ្លះ ? ហេតុអ្វីបានជាគេធ្វើម៉ែត្រច្រើនយ៉ាង ? អ្នកណាខ្លះប្រើម៉ែត្រអស់នេះ ? ហេតុដូចម្តេចបានជាជាងឈើប្រើម៉ែត្របត់ឈើ ? ជាងដែកប្រើម៉ែត្រស្ពាន់ ? ជាងកាត់សំលៀកបំពាក់ប្រើម៉ែត្រសំពត់ ? អ្នកលក់សំពត់ប្រើម៉ែត្របន្ទាត់ឈើ ?

សូមឲ្យសិស្សទាយស្មានប្រវែង ទទឹង បណ្តោយ កំពស់ វត្ថុដែលមាននៅក្នុងបន្ទប់រៀន រួចទើបយកម៉ែត្រមកវាស់មើល ។

## ២.– ហាត់សរសេរ

**បំណោទ.–** ចិនម្នាក់ទិញសំពត់ ១០ ម៉ែត្រ លក់ ៦ ម៉ែត្រ

ទៅវិញ តើចិននោះនៅសល់ប៉ុន្មានម៉ែត្រ ? ។ — គឺព្រឹកមិញក្ដាយខ្ញុំទិញទេសឯក ២៥ ម៉ែត្រ ហើយទិញ ៥៨ ម៉ែត្រទៀត គាត់យកទៅលក់អស់ ៦៣ ម៉ែត្រ តើគាត់នៅសល់ទេសឯកប៉ុន្មានម៉ែត្រទៀត ។

## អាទិត្យបន្ទាប់ .— អំពីលីត្រ

សូមរករង្វាល់លីត្រគ្រប់មុខមកបង្ហាញសិស្ស បើគ្មានសូមគូររូបបង្ហាញគំនូរ ។

លីត្រសំរាប់វាល់ចំណុះ ឬ គ្រាប់សារពើទាំងឡាយ ។ លីត្រមានច្រើនយ៉ាង មានលីត្រសំណប៉ាហាំង លីត្រស៊ីវិឡាត សំរាប់វាល់វត្ថុរាវ លីត្រឈើសំរាប់វាល់គ្រាប់ លីត្រដបក៏មានដែរ ។

លីត្រគេសរសេរកាត់យ៉ាងដូច្នេះ "ល" ដូចជា ៦ លីត្រ = ៦.ល ។ ១៥ លីត្រ ១៥.ល ។ ល ។ គេមានប្រើលីត្រគោរគឺ — ចំណុះ ២ លីត្រដែរ ។

## ១.— ហាត់គិតមាត់ទទេ —

បើកាលណាគេចង់ដឹងចំណុះវត្ថុទាំងឡាយ គេត្រូវប្រើអ្វី ។ លីត្រ-មានប៉ុន្មានយ៉ាង ? លីត្រឈើសំរាប់វាល់អ្វី ? លីត្រដែកស្ពាន់សំរាប់វាល់អ្វី ។

តើត្រូវប៉ុន្មានកន្លះលីត្រក្នុង ១៤លិ. ? ១៨លិ. ? ១៧លិ ? ១៩លិ. ?

តើត្រូវប៉ុន្មានលីត្រកន្លះក្នុង ៣៩លិ. ? ៤៤លិ. ? ៣៦លិ. ?

## ២ .– ហាត់សរសេរ

បំណោទ .– ចិនម្នាក់លក់ស្រាមួយលើកអស់ ២៥លិ. លើកបន្ទាប់អស់ ៤៣ លីត្រ លើកក្រោយបង្អស់ ២៨លិ. តើចិននោះលក់ស្រាទាំងអស់បានប៉ុន្មានលីត្រ? ។

គេចាក់ប្រេងកាតទៅក្នុងធុងម្តង ១៥ លីត្រ ម្តងទៀត ៨ លីត្រ លើសលើកមុន តើធុងនោះចំណុះប្រេងកាតប៉ុន្មានលីត្រ ? ។

# មជ្ឈិមដ្ឋានទី ១

## រង្វាស់រង្វាល់

### អាទិត្យដំបូង .– អំពីម៉ែត្រ

ម៉ែត្រជារង្វាស់ខ្នាតដើមនៃវិធីវាស់ប្រវែង គេប្រើសំរាប់វាស់ ប្រវែង ទទឹង បណ្តោយ កំពស់ និងជំរៅ វត្ថុទាំងឡាយដូចជាក្តារជើ ក្តារខៀនបញ្ជរ បន្ទប់រៀន ។ល។ ម៉ែត្រមានច្រើនយ៉ាង គឺម៉ែត្រឈើបន្ទាត់ ម៉ែត្រឈើបត់ ម៉ែត្រដែកឬស្ពាន់បត់ ម៉ែត្រសំពត់ ប៉ុន្តែម៉ែត្រទាំងនេះប្រវែងស្មើគ្នាទាំងអស់ ជាខ្នាតទៀងណាស់ ហើយបាន

ដាគេធ្វើឲ្យមានច្រើនបែបនេះ គឺឲ្យងាយដល់អ្នកប្រើការ ។ ឈ្មួញសំពត់ប្រើម៉ែត្របន្ទាត់ ជាងធ្វើផ្ទះជាងឈើប្រើម៉ែត្របត់ធ្វើទីងឈើធ្វើទីងដែក ជាងដេរខោអាវ ប្រើម៉ែត្រសំពត់ ម៉ែត្រគេសរសេរកាត់ "ម" ១ម៉ែត្រ = ១$^{ម}$, ២ម៉ែត្រ = ២$^{ម}$, ៣$^{ម}$, ។

## ១._ បាត់គិតមាត់ទទេ

**ម៉ែត្រសំរាប់ធ្វើអ្វី .–** ម៉ែត្រមានប៉ុន្មានយ៉ាង ? ម៉ែត្រអ្វីខ្លះ ? ម៉ែត្រណាវែងជាងគេ ? ហេតុអ្វីបានជាគេធ្វើម៉ែត្រច្រើនយ៉ាង ? ជាងដេរខោអាវប្រើម៉ែត្រអ្វី ? ជាងឈើប្រើម៉ែត្រអ្វី ? រូបបង្ហាត់សិស្សឲ្យទាយស្មានប្រវែង ទទឹង បណ្ដោយ កំពស់ រួចឲ្យយកម៉ែត្រមកវាស់មើល ។

## ២ ._ បាត់សរសេរ

**បំណោទ .–** ចិនម្នាក់ទិញសំពត់ ៣៩ ម៉ែត្រហើយលក់ ៦ ម៉ែត្រទៅវិញ តើចិននៅសល់ប៉ុន្មានម៉ែត្រ? ។

ឈ្មួញម្នាក់ទិញសំពត់ ៧៥ ម៉ែត្រ ម្ដងទៀត ២៥ ម៉ែត្រ ឈ្មួញនោះយកទៅលក់វិញអស់ ៥៣ ម៉ែត្រ តើគេនៅសល់ប៉ុន្មានម៉ែត្រលក់ទៀត? ។

# អាទិត្យបន្ទាប់ អំពីលីត្រ

សូមឲ្យគេរង្វាល់មកឲ្យសិស្សពិនិត្យ បើគ្មានសូមឲ្យបង្ហាញគំនូរ ឬគូរឲ្យមើល ។ លីត្រជារង្វាល់ប្រើសំរាប់វាល់វត្ថុរាវ ដូចជាស្រា ប្រេង ខ្លាញ់ ទឹក និងវត្ថុគ្រៀមឬគ្រាប់ ដូចជាអង្ករ ស្រូវ សណ្តែក ល្ង ។ល។ លីត្រមានចំណុះស្មើគ្នាទាំងអស់ ប៉ុន្តែមានបែបខុសគ្នា រង្វាល់លីត្រដែលមានដាក់ស្តង់នោះមាន ៣ យ៉ាង ។

១ – លីត្រធ្វើនឹងដែកសវិឡាត ឬសំណប៉ាហាំងមានដៃកាន់ពីក្រោយសំរាប់វាល់ ខ្លាញ់ ប្រេង ទឹក ។ល។

២ – លីត្រធ្វើនឹងស្ពាន់ស មានដៃយួរសំរាប់វាល់ស្រា ទឹកដោះគោ ។

៣ – លីត្រធ្វើនឹងឈើសំរាប់វាល់វត្ថុគ្រៀមដូចជាម្សៅ ពោត អង្ករ ស្រូវ ល្ង សណ្តែក ។ល។ មានលីត្រមួយយ៉ាងទៀតហៅថាលីត្រដប-

ឯលីត្រដបនេះគេធ្វើសំរាប់ដាក់ស្រា ដាក់ទឹកថ្នាំនិងវត្ថុឯទៀតរាវដូចជាទឹកហើយលីត្រនេះគេពុំមែនប្រើសំរាប់វាល់ដូចជាលីត្រឯទៀតនោះទេ គឺគេធ្វើសំរាប់ដាក់ស្រាឬថ្នាំ ឲ្យដឹងចំនួនទឹងកំណត់ ។

នៅក្នុងផ្ទះជំនួញធំ ៗ នោះមានឃើញលីត្រធ្វើនឹងដែក ហើយនិងស្ពាន់ក្រហម ប៉ុន្តែរង្វាល់ដែលធ្វើនឹងដែកហើយនិងស្ពាន់ក្រហមនេះ ច្រើនជារង្វាល់ធំជាងលីត្រ ។

## ១ ហាត់គិតមាត់ទទេ

គេហៅរង្វាល់ដែលជាប្រធានមានជាជាក់ស្ដែងគឺអ្វី ? បើគេចង់ដឹងចំនួនវត្ថុរាវដែលគេថ្លឹងពុំស្រួលនោះគេធ្វើដូចម្ដេច ? លីត្រជាអ្វី ? មានប៉ុន្មានយ៉ាង ? លីត្រឈើសំរាប់ប្រើធ្វើអ្វី ? ចោទសួរពីចារណា អំពីរង្វាល់លីត្រដែលធ្វើផ្សេង ៗ ហើយនិងប្រយោជន៍លីត្រ ៗ លីត្រ ផងប្រយោជន៍វា ហើយឲ្យចំណាំថា ផងអ្វីដែលចំណុះមួយលីត្រ ៗ ត្រូវ ឲ្យសិស្សដឹងថារង្វាល់ឯណា ឈ្មោះតែលីត្រនោះ គឺចំណុះស្មើគ្នាទាំងអស់ ខ្មែរយើងគ្មានទេរង្វាល់បែបនេះ បើគេត្រូវការវាល់អ្វីរាវ ៗ នេះគេច្រើន ប្រើពែងហើយនិងចាន ដែលតែងតែមានធំតូចជាងគ្នាដរាបឥតមាន ទៀងទាត់ទេ ។ បើមានរង្វាល់លីត្រ ឲ្យសិស្សវាល់ទឹក ស្រូវ អង្ករ អង្កាម ដីខ្សាច់ វាល់ទឹកដាក់ចាក់ក្នុងប៉ោតប្រេងកាតមួយ ហើយសំគាល់ ថាប៉ោតនេះចំណុះ ១៨ លីត្រ ឲ្យវាល់អង្ករដាក់ក្នុងតៅមួយ ហើយបើ តៅនេះត្រូវខ្នាតនឹងឃើញមានចំណុះ ១៥ លីត្រ រួចបង្ហាត់ស្មានហើយ-វាល់មើល ។

## ២- ហាត់សរសេរ

នៅក្នុងពាងខ្ញុំមានទឹក ២៧ លីត្រ បើខ្ញុំដួសយកទឹកនោះ ១៨ លីត្រចេញ តើនៅសល់ទឹកប៉ុន្មានលីត្រក្នុងពាងទៀត ?

២– ទឹកនៅក្នុងធុងមាន ៨០ លីត្រ គេប្រើការអស់ ៤០ លីត្រ ហើយគេដងទឹកដាក់ថែម ១២ លីត្រមកវិញ តើនៅក្នុងធុងមានទឹកប៉ុន្មានលីត្រ ?

## មេរៀនទី ២.- អំពីក្រាម

វត្ថុដែលគេវាល់មិនបាន វាស់ពុំកើតនោះ គេត្រូវថ្លឹងទម្ងន់ គេថ្លឹងនឹងជញ្ជីង ហើយនឹងកូនទម្ងន់ ឯកូនទម្ងន់សំរាប់ថ្លឹងទំនិញឬរបស់ស្រាល ៗ នោះគឺ ក្រាមជាដុំស្ពាន់តូចមូលសំប៉ែត្រមានក្បាលមួយសំរាប់កាន់ ។ ក្រាម សរសេរកាត់យ៉ាងដូច្នេះ "ក្រ" សូមយកជញ្ជីងកូនទម្ងន់ដែលហៅថាក្រាម ហើយនឹងវត្ថុសំរាប់ថ្លឹងនោះមកបង្ហាញសិស្សមើល ហើយប្រាប់របៀបដែលថ្លឹង រួចហើយឲ្យសិស្សរៀនថ្លឹងឲ្យបានច្រើនគ្នា លុះត្រាតែចេះបំណាំទម្ងន់វត្ថុ ជានេះ ១ ក្រាម – ៥ ក្រាម – ១០-ក្រាម – ២០ ក្រាម ។

## ១– ហាត់គិតមាត់ទទេ

គេថ្លឹងរបស់សព្វសារពើនឹងអ្វី ? ពីព្រោះអ្វីបានជាគេថ្លឹង ? វត្ថុណាខ្លះដែលគេត្រូវថ្លឹង ? កូនជញ្ជីងជាមេហៅថាអ្វី ? នឹងថ្លឹងគេធ្វើដូចម្ដេច ?ល?

## ២ ហាត់គិតនៅក្ដារខៀន

ត្រូវជាប៉ុន្មាន ១៧ ក្រ នឹង ៨១ ក្រ ? ៤១ ក្រ នឹង ១៧ ក្រ ?ល?

វត្ថុនេះទម្ងន់១២ ក្រ វត្ថុនោះទម្ងន់ ១៩ ក្រ វត្ថុទាំងពីរមានទម្ងន់ប៉ុន្មានក្រាម?

សូមធ្វើយ៉ាងដូច្នេះព្រមទាំងលេខបូកនឹងសងមានត្រាទុកឬឥតត្រាទុក ផងចុះ ?

## ៣ – ហាត់សរសេរ

បំណោទ .– ខ្ញុំមានខ្សែមាសពីរខ្សែទម្ងន់ ៣៤ ក្រាម ខ្សែមាសមួយទម្ងន់ ២៥ ក្រាម តើខ្សែមាសមួយទៀតទម្ងន់ប៉ុន្មានក្រាម ?

ម្ដាយខ្ញុំយកមាសទៅឲ្យជាងទង់ធ្វើម្ដង ២៨ ក្រាម ម្ដងទៀតលើសមុន ៩ ក្រាម តើរបស់នោះទម្ងន់ប៉ុន្មានក្រាម ?

មធ្យមដ្ឋានទី ១ ទឹន អាទិកដ្ឋាន

## ធរណីមាណសាស្ត្រ

អាទិត្យទី ១.– បន្ទាត់- បន្ទាត់មានទំហំតែមួយគឺ ប្រវែង ។ រាងនៃបន្ទាត់- ទ្រនុងគុកងជា បន្ទាត់ត្រង់ ឈ្មោះរណារជា បន្ទាត់កាច់ ហាមមួកជា បន្ទាត់កោង ។

អត្ថន័យ.– ១- បន្ទាត់ត្រង់ គឺជាផ្លូវខ្លីបំផុតពីចំណុចមួយទៅចំណុចមួយ ។

២ – បន្ទាត់កាច់- កើតពីបន្ទាត់ត្រង់ច្រើនតគ្នា ។

៣ – បន្ទាត់កោង- គឺជាបន្ទាត់មិនមែនត្រង់មិនមែនកាច់ ។

សុំគ្រូឲ្យសិស្សរករបស់អ្វីដែលមានសណ្ឋានដូចបន្ទាត់ទាំងនេះ ។

អាទិត្យទី ២.– លក្ខណភាពរបស់បន្ទាត់ត្រង់- ផ្ទៃទឹកក្នុងកែវ មានសណ្ឋានជា បន្ទាត់ផ្ដេក ខ្សែកូនប្រយោលដែលធ្លាក់ត្រង់ចុះ

មានលំនាំជា **បន្ទាត់ឈរ** ឬនឹងបួលផ្អូរមានសណ្ឋានជា **បន្ទាត់ផ្អៀង** គែមក្តារខៀនលើនឹងក្រោមមានសណ្ឋានជាបន្ទាត់ស្រប ។

សុំគ្រូបង្វឹកសិស្សឲ្យស្គាល់ស្ថានភាពបន្ទាត់នេះដោយឲ្យគូរគំនូរខ្លះ តាមក្បួននព្វន្តសំរាប់អាទិកដ្ឋានទំព័រទី ១១៧-១១៨-១១៩ និង ១២០ ។

---

# បរិច្ឆណដ្ឋាន

## នព្វន្ត

មេរៀនទី ១.– សាបញ្ជាក់អំពីចំនួនពី ១ ដល់ ៩៩ ដែលសិស្សបានរៀនពីថ្នាក់កុមារដ្ឋានមក ។

របស់សំរាប់បង្រៀន .– បន្ទើះកយ-បន្ទើះបាច់ឬលុយសេននឹងប្រាក់កាក់ ។

របៀបបង្រៀន .–

១- ការហាត់គិតមាត់ទទេ.– ឲ្យសិស្សរាប់បន្ទើះឬលុយបន្ថែម ២-៣-៤...ពី ៩៩ មកវិញ ។

២– ការហាត់បញ្ជាក់ក្នុងការរៀនមើលចំនួន.– ចង្អុលចំនួនដែលសរសេរទុកនៅលើក្ដារខៀនឲ្យសិស្សមើលថា – សួរសាកបញ្ជាក់អំពីខ្ទង់ដប់និងខ្ទង់កាយ ។

៣– ការហាត់បញ្ជាក់ក្នុងការសរសេរចំនួន.– គ្រូថាចំនួនឲ្យសិស្សសរសេរនៅលើក្ដារឆ្នួនតាមរបៀប "ឡាមារទីនីញែរ" ។

៤– ការហាត់សរសេរនៅក្នុងសៀវភៅ.–

១៧ ស+៤ ស=...ស ។ ២៩ ស+៣ ស=... ស ។

៤៦ ស+១០ ស=...ស ។ ៧៣ ស+២០ ស=... ស ។

៩២ ស–៥ ស=...ស ។ ៨៧ ស–១៧ ស=... ស ។

៦១ ស–៤ ស=...ស ។ ៧៥ ស–២៥ ស=... ស ។

បំណោទ.– ខ្ញុំមានលុយ ៩២ សេន ម្ដាយខ្ញុំឲ្យខ្ញុំ១៥ ស ឪពុកខ្ញុំឲ្យខ្ញុំ ២៣ សេន ខ្ញុំត្រូវមានលុយទាំងអស់ .....សេន ដល់ខ្ញុំឲ្យទៅប្អូនខ្ញុំ ៣០ សេនទៅខ្ញុំត្រូវនៅសល់លុយ ....សេន. ។

មេរៀនទី២.– សាបញ្ជាក់អំពីលេខបូកដែលសិស្សបានរៀនរួចពីថ្នាក់កុមារដ្ឋានមក ។

របស់សម្រាប់បង្រៀន ។– ចង្កឹះ – គ្រាប់ក្រួសឬលុយទុកឲ្យសិស្សរាប់ ។

១– ការហាត់គិតមាត់ទទេ ។– ឲ្យសិស្សរាប់របស់បន្ថែម ២–៣–៤– ពី១ដល់៩៩ ។

២– ការហាត់បញ្ជាក់នៅលើក្ដារខៀន ។– គ្រូចោទជាចំណោទយ៉ាងងាយដែលសិស្សត្រូវរកចម្លើយឃើញដោយធ្វើលេខបូក ហើយឲ្យសិស្សធ្វើលេខនោះនៅលើក្ដារខៀន – បើពិនិត្យទៅឃើញថាសិស្សពុំទាន់ចេះធ្វើលេខបូកនោះស្ទាត់ទេ គ្រូត្រូវឆ្លៀតឱកាសពន្យល់ឲ្យសិស្សចេះប្រាកដឡើង ។ ៣៥រ + ២៣រ = ។ ៤៧រ + ៣៤រ = ៦៤រ + ៣៩រ = ។ ៥៦រ + ១៩រ = ។

ការហាត់បញ្ជាក់នៅលើក្ដារខៀន ។–

១៧ស + ២១ស = ។ ៤៣ស + ៣៦ស = ... ។

៥៧ស + ២៥ស = ។ ៤៦ស + ៣៧ស = ... ។

៤ ការហាត់សរសេរនៅក្នុងសៀវភៅ ។–

| | | | |
|---|---|---|---|
| ២៣ស | ៤២ស | ៣៧ស | ៤៦ស |
| + ៣៨ស | + ២៧ស | + ៤៩ស | + ៣៧ស |
| ——— | ——— | ——— | ——— |

ចំណោទ – ខ្ញុំទិញសៀវភៅមើលមួយថ្លៃ២៥៛ ហើយនឹងសៀវភៅសរសេរ១០ថ្លៃ៣៧រៀល ។ តើខ្ញុំចាយអស់ប្រាក់ប៉ុន្មាន? ។

មេរៀនទី៣ .— សាកបញ្ជាក់អំពីលេខសង់ដែលសិស្សបានរៀនចេះពីថ្នាក់កុមារដ្ឋានមក ។

សូមមើលតាមរបៀបខាងលើនេះ ហើយសូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

## រង្វាស់ រង្វាល់

មេរៀនទី ១ .— អំពីរង្វាស់ម៉ែត្រ (ម)

របស់សំរាប់បង្រៀន .— ម៉ែត្របត់ ។

របៀបបង្រៀន .—

១ – ការពិនិត្យរូបរង្វាស់ : – គ្រូបង្ហាញម៉ែត្រឲ្យសិស្សមើល – សរសេរពាក្យម៉ែត្រនៅលើក្ដារខៀនជាអក្សរពុំផង និងជាអក្សរកាត់ ។ នាំសិស្សពិនិត្យមើលរូបរាងនឹងប្រវែង ១ម . ហើយសួរសាកបញ្ជាក់ឡើងវិញ ។

ពាក្យចោទ .– ម៉ែត្រសំរាប់ធ្វើអ្វី ? អ្នកណាខ្លះដែលត្រូវការប្រើម៉ែត្រ ? ម៉ែត្រនេះមានរូបរាងដូចម្ដេច ? ។

**២ ការហាត់ស្មាននិងហាត់វាស់** .– គ្រូបង្ហាញប្រវែង ១ម. ឲ្យសិស្សពិនិត្យ – ឲ្យសិស្សរករបស់អ្វីដែលមានប្រវែង ១ម. ឬឲ្យស្មានប្រវែង ១ម. ឲ្យសិស្សវាស់បញ្ជាក់លើការស្មាននោះ ។

ឲ្យសិស្សវាស់បញ្ជាក់លើការស្មាននោះនាំសិស្សស្មាន ហើយវាស់បញ្ជាក់នេះឲ្យបានច្រើន ។

## ៣ – ការហាត់គិត .–

៥ម + ៧ម= ... ។ ១៧ម + ៣៥ម= ... ។

៤៧ម – ២៣ម= ... ។ ៧១ម – ៣៥ម= ... ។

## ៤ – ការហាត់សរសេរនៅក្នុងសៀវភៅ

១៥ម + ៧ម= ... ។ ៣៤ម + ៨ម= ... ។

៧៥ម – ២៥ម= ... ។ ៦២ម – ៧ម= ... ។

បំណោទ .– ជាងដេរខោអាវម្នាក់មានសំពត់ ៤៧ម. ត្រូវកាត់ខោ

១៩ អស់សំពត់ ២ម ក្នុងមួយ តើដាច់នោះត្រូវនៅសល់សំពត់ប៉ុន្មានម៉ែត្រទៀត ។

## មេរៀនទី ២.– អំពីម៉ែត្រគ្រប់បែប

សូមលោកគ្រូរកម៉ែត្រគ្រប់បែបមកបង្ហាញសិស្ស – នាំសិស្សពិនិត្យមើលរូបរាងម៉ែត្រគ្រប់បែប ហើយពន្យល់របៀបប្រើប្រាស់ហើយ សូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

---

# កុមារដ្ឋាន

## នព្វន្ត

### ចំនួន ពី „០‟ ដល់ „៩‟

សេចក្ដីសំខាន់ .– វេលាដែលបង្រៀននព្វន្តម្ដងៗ កុំឲ្យបង្រៀនតែលេខទទេ ត្រូវឲ្យមានវត្ថុផ្សេងៗ ដូចជា : ចង្កឹះ , ចំរៀកឫស្សី , ដុំក្រួស , ដងប៉ាកកា , លុយសេន , ដីស ..... ។ល។ ដើម្បីឲ្យសិស្សរៀនរាប់ ។

## របៀបបង្រៀន ៈ-

បំណួន "០" .- ក) - គ្រូលើកប្រអប់ទទេបង្ហាញសិស្ស ហើយសួរសិស្សថា: ក្នុងប្រអប់នេះមានដីសប៉ុន្មានដុំ ? សិស្សឆ្លើយថា: គ្មានឬសូន្យ ។ ពាក្យ "គ្មាន" "ឬ" "សូន្យ" នេះគ្រូឲ្យសិស្សថាឲ្យច្បាស់ៗ ខ្លាំងៗ ឲ្យបានច្រើនគ្នា ។

១)- គ្រូសរសេរលេខ ០ នៅក្ដារខៀនបង្ហាញសិស្ស , ឲ្យសិស្សមើល , ឲ្យសិស្សសរសេរ នៅក្ដារខៀនហើយនិងនៅក្ដារឆ្នួន លើកឲ្យគ្រូមើលពិនិត្យឲ្យត្រឹមត្រូវ ។

(លេខក្រោយ ២ មកទៀត ក៏ត្រូវធ្វើដូចរបៀបនេះដែរ) ។

គ)- គ្រូសួរឲ្យសិស្សគិត - ឯងមាននាឡិកាឬទេ ? (គ្មាន ឬ សូន្យ)- ស្រុកខ្មែរយើងមានរោងមាស៊ីនធ្វើកប៉ាល់ ឬ យន្តហោះ ឬទេ ? (គ្មាន ឬ សូន្យ)- ។ល។....

បំណួន ១ .-- ក)- គ្រូកាន់ចង្កឹះ ១ ហើយប្រាប់សិស្សថា នេះចង្កឹះ (១) ។

១)- គូសគំនូសចង្កឹះ ១ នៅក្ដារខៀន ។

គ)- សរសេរលេខ ១ នៅក្រោមគំនូស

ឃ)- សួរសិស្សឲ្យគិត - ឯងមានក្បាលប៉ុន្មាន? មានដងខ្លួនប៉ុន្មាន?

ង)- សួរសិស្សឲ្យបង្ហាញ: ចូរឯងបង្ហាញដៃមួយ - សៀវភៅមួយ ទ្វារមួយ ។

ចំនួន ២.- ក)- គ្រូកាន់ចង្កឹះ ១ នៅដៃស្ដាំ ហើយ ១ ទៀត នៅដៃឆ្វេង រួចប្រមូលចង្កឹះទាំង ២ នៅដៃតែម្ខាង ហើយប្រាប់សិស្ស ថា នេះចង្កឹះ ២ ។

ខ)- គូសគំនូសចង្កឹះ ២ នៅក្ដារខៀនហើយសរសេរលេខ ២ ពីក្រោម (ធ្វើដូចជាលេខ ១). ។

គ)- សួរសិស្សឲ្យគិត. ឯងមានដៃ, ជើង, ភ្នែក, ត្រចៀក, ប៉ុន្មាន? ក្នុងថ្នាក់យើងមានក្ដារខៀនប៉ុន្មាន? ... ។ល។

ចំនួន ៣.- ក)- គ្រូបង្ហាញចង្កឹះម្ដង ១ៗ គ្រប់ ៣ ទើបប្រាប់សិស្សថា: នេះចង្កឹះ ៣ ។

ខ)- គូសគំនូស ៣ ហើយត្រាលេខ ៣ ពីក្រោម (ធ្វើដូចលេខមុនៗ)

គ)– សួរសិស្សឲ្យគិត –: ត្រីចក្រយាន (ស៊ីក្លូ) មានកង់ប៉ុន្មាន? ចូរឯងមើលជណ្ដើរថ្នាក់រៀនយើងមានកាំប៉ុន្មាន? (រើសជណ្ដើរដែលមានកាំ ៣ ). ។ ចូរឯងគូសជើងក្អែក ៣ នៅលើក្ដារខៀន ។

បំប្លង ៤.–ក)– គ្រូបង្ហាញបង្កើះម្ដង ១ ។ បូកម្ដង ២ ។ បូកម្ដង ៣ នឹងម្ដង ១ ហើយប្រាប់សិស្សថានេះបង្កើះ ៤ ។

១)– គូសគំនូស ៤ ហើយត្រាលេខ ៤ ពីក្រោម - ឲ្យសិស្សមើល- ឲ្យសិស្សថា, សរសេរ ដូចលេខមុន ៗ ។

គ)–សួរសិស្សឲ្យគិត .– ឆ្មា, ឆ្កែ, សេះ, គោ, ក្របី, ជ្រូក, ដំរី, សត្វអស់នេះមួយ ៗ មានជើងប៉ុន្មាន ? ចំនួន ៥, ៦, ៧, ៨, ៩, – របៀបបង្រៀនដូចលេខមុន ៗ ។

## វិធីហាត់គិត , សរសេរសាពីដើម

ឯងមានម្រាមដៃប៉ុន្មាន ? លោកគ្រូមានកៅអីប៉ុន្មាន ? អាវនេះមានហោប៉ៅប៉ុន្មាន ? ចូរឯងសរសេរលេខ ៣ ; ៦ ; ២ ; ០ ; ៩; ៧ ; ៥ ; ។ល

បង្រៀនគិតរកចំនួននឹងប្រាជ្ញា ( មតិសំខ្យា )

គ្រូពោលថា = បន្ទាត់ ៦ បើបាត់អស់ ១ តើនៅសល់បន្ទាត់ប៉ុន្មាន?

( បង្ហាញចំនួនបន្ទាត់ផង ) ។ សិស្សឆ្លើយមាត់ទទេសិន សឹមសរសេរលេខតាមក្រោយ ។ ចៅឪមានដីស ១ ដុំ - គ្រូឲ្យដីស ៣ ដុំទៀត - តើចៅឪមានដីសប៉ុន្មានដុំ? ។

សត្វព្រាបទំតម្រៀបគ្នាជាជួរមានទាំងអស់ ៩ ព្រានបាញ់ស្លាប់អស់ ២ របួស ១ - តើហើររត់បាត់ទៅប៉ុន្មាន ? ។

( សូមគ្រូ កុំប្រញាប់ ស្រូតពេក ក្នុងការបង្រៀន លេខទាំងដប់បែបនេះ ព្រោះក្មេង ដែលទើបចូលរៀនថ្មីៗដំបូងចេះតែថាមេលេខនីមួយៗ ដោយស្ដាប់តគេថារាល់ៗថ្ងៃ

ប៉ុន្តែត្រង់សរសេរវិញនៅឆ្គងណាស់ ) ។

## កុមារដ្ឋាន

### វង្វាស់វង្វាល់

### អំពីម៉ែត្រ

ប្រដាប់បង្រៀន.– ត្រូវយកម៉ែត្រទាំង ៣ យ៉ាង គឺ: ម៉ែត្រ

បន្ទាត់១ ម៉ែត្របត់មាន៥ ឬ ១០ ផ្នត់ ១ ម៉ែត្រសំពត់ ១ មានម៉ែត្រ

ឈើ - ស្ពាន់- ដែក- ខ្សែ ១ បន្ទាយ ។

របៀបបង្រៀន៖— ក) - ការពិនិត្យ មើលរង្វាស់ ម៉ែត្រ

១) - សូមលើកម៉ែត្រណា ១ឲ្យខ្ពស់ឡើងបង្ហាញ ឲ្យសិស្សឃើញ គ្រប់គ្នា ។ ឲ្យសិស្សពិនិត្យរូបរាងម៉ែត្រទាំងបីយ៉ាង ហើយប្រាប់សិស្សថានេះរង្វាស់ ហៅថា "ម៉ែត្រ" ។

២) ឲ្យសិស្សកាន់ ពិនិត្យ ប្រវែង, ទំហំ , រាង ,ពណ៌, លេខ,ធម្មជាតិវត្ថុយកមកធ្វើម៉ែត្រនោះ . . . ។

៣) គ្រូសរសេរ ពាក្យ "ម៉ែត្រ" នៅក្ដារខៀន ( សរសេរគ្រប់តួមក្សរទាំងសរសេរកាត់ "ម"

៤)- ម៉ែត្រទាំងអស់ ដូចគ្នាឬទេ?

ហេតុដូចម្ដេចបានជាគេធ្វើឲ្យខុសគ្នាយ៉ាងនេះ ? ( ប្រើការមិនដូចគ្នា) ប្រវែងគ្នាឬទេ? (ឲ្យសិស្សពីរ ឬ បី នាក់ យកម៉ែត្រទាំងប៉ុន្មានមកវាស់ផ្ទៀងគ្នាមើលឲ្យឃើញជាក់ជាប្រវែងគ្នាមែន ។

៥ ). សួរសិស្សឲ្យរករបស់អ្វីណាមួយ នៅក្នុងក្នុងរៀនដែល

មានបណ្ដោយ ទទឹងឬកំពស់ប្រវែងតែ ១ ម៉ែត្រ ហើយឲ្យរើសខ្លួនឯងយកម៉ែត្រណាដែលត្រូវវាស់របស់នោះ ។

## ខ)· វិធីវាស់ប្រវែងរបស់ផ្សេងៗដោយស្មាន និងវិធីវាស់បញ្ជាក់នឹងម៉ែត្រ·

១). ប្រាប់សិស្សទាំងអស់គ្នាឲ្យស្មាន ប្រវែងបណ្ដោយនៃបន្ទប់រៀន, ស្មានប្រវែងទទឹង ស្មានកំពស់តុ: គ្រូ, ស្មានទទឹងទ្វារសាលា ...។ល។

២)- សិស្សស្មានហើយ សូមត្រាពាក្យឆ្លើយនៅក្ដារខៀនខ្លួនៗ

៣)-សូមគ្រូគត្រាមើល បើឃើញសិស្សណាឆ្លើយស្មានខុសច្រើនពីសិស្សដទៃឲ្យសិស្សនោះយកម៉ែត្របត់ឬម៉ែត្របន្ទាត់ទៅវាស់បញ្ជាក់ ។ ក្នុងការវាស់នេះ គ្រូត្រូវបង្ហាញសិស្សឲ្យបានឃើញច្បាស់គ្រប់គ្នាពីរបៀបកាន់ម៉ែត្រវាស់ឲ្យត្រឹមត្រូវ ។

## គ)· ការហាត់គិតសរសេរនៅក្ដារខៀនឬនៅក្នុងសៀវភៅ

ឈ្មួញម្នាក់មានសំពត់១ផាប់តួបប្រវែង ៦ ម៉., គេលក់អស់ ៣ ម៉., តើ

នៅសល់សំពត់ប៉ុន្មានម៉ែត្រទៀត? (ការហាត់សរសេរ ហាត់គិតមាត់ទទេ សូមលោកគ្រូលៃលកធ្វើឲ្យបានច្រើន នៅក្ដារខៀនក្ដី នៅក្នុងសៀវភៅក្ដី) ។

---

## មជ្ឈិមដ្ឋាន ទី២ និង ឧត្ដមដ្ឋាន

## សេចក្ដីណែនាំ នៃរបៀបបង្រៀនវត្ថុស្គាល់ធម្មជាតិ

ការបង្រៀនវត្ថុស្គាល់ធម្មជាតិជាកិច្ចមួយដ៏ពិបាក តែបើមានសេចក្ដីព្យាយាមបន្តិចនឹងរកវត្ថុដែលត្រូវបង្រៀនឲ្យមានគ្រប់គ្រាន់ ឃើញថាមិនសូវពិបាកប៉ុន្មានទេ ។ មេរៀននីមួយ ៗ គ្រូបង្រៀនតាមរូបរបស់ដែលត្រូវយកមកបង្រៀន ឯកិច្ចបង្រៀនវត្ថុស្គាល់ធម្មជាតិដូចមានខាងក្រោមនេះ ៖

## ក– ការនាំសិស្សពិនិត្យមើល ៖

១ – មើលនឹងភ្នែក .– រូបរាង – ទ្រង់ទ្រាយ . (ប្រដូចនឹងរបស់ឯទៀត) ពណ៌ (ប្រដូចនឹងពណ៌វត្ថុឯទៀត បើត្រូវការ) – ស្រអាប់ ថ្លាដូចជាកែវ, កញ្ចក់ . ។ ល ។ .

២–ស្ទាបនឹងដៃ .– វត្ថុនោះរលីងឬគគ្រាត , ត្រជាក់ឬក្ដៅ –

៣–លើកទម្ងន់ . ស្រាលឬធ្ងន់ ( ដូចអ្វី ) ធំឬតូច ( ដូចអ្វី ).

៤–ពិនិត្យក្លិន .– ក្លិនក្រអូប – ឈ្ងុយ – ឈ្ងៀម – ស្អុយ ។ល។ ប្រដូចទៅក្លិនវត្ថុឯទៀត ៗ

៥–ពិនិត្យរសជាតិ .– ឲ្យដឹងថាវត្ថុនោះប្រៃ – ជូរ – ល្វីង – ផ្អែម ។ល។

៦ – ពិនិត្យឲ្យដឹងសូរ .– ឮសូរតិចឬខ្លាំង បើវាយវត្ថុនោះទឹង បន្ទាត់ ឬគ្មានសូរទេ ។ល។.

## ១–ការប្រើឲ្យដឹងប្រយោជន៍នៃវត្ថុ·

នាំសិស្សរកផលប្រយោជន៍វត្ថុនិមួយ ៗ ហើយបញ្ជាក់ប្រយោជន៍នោះឲ្យឃើញច្បាស់នឹងភ្នែកទៀតផង ដោយមានរបស់បង្ហាញសិស្សភ្លាម ៗ ឬដោយបានបង្រៀនឬបានឃើញពីមុន ៗ មក ។

## គ – ការពិសោធន៍ឲ្យសិស្សមើល

១ – យកវត្ថុនោះទៅដាក់ក្នុងទឹក – វត្ថុនោះរលាយឬទេ ? បើសិនណាជាដាក់ទៅក្នុងទឹកត្រជាក់ឬទឹកក្ដៅ ៗ

២ – យកវត្ថុនោះទៅដុតភ្លើង ឲ្យសិស្សនិយាយតាមដែលបានឃើញ, បានធុំក្លិនវេលាកំពុងតែដុតនោះ ។ល។

ការចំណាំទុក .– នៅវេលាដែលសួរបុត្រពន្យល់មេរៀននោះ លោកគ្រូត្រូវសរសេរលើក្តារខៀនបញ្ឈរ ពាក្យណាដែលសិស្សមិនទាន់ចេះ នឹងបានចំណាំអក្សរ នឹងរៀនសព្ទនៃពាក្យនោះប្រយោជន៍បាន ប្រើការទៅថ្ងៃក្រោយ ឲ្យបានត្រឹមត្រូវក្នុងការចងផ្ញើជាឃ្លា ឬ តែងសេចក្តីឬក្នុងការនិយាយជាប្រសើររបស់សិស្សថែមទៀតផង ។ល។

## វត្ថុភាធ្យាយន៍

### អាទិត្យទី ១.– អំពីខ្លួនមនុស្ស

ប្រដាប់បង្រៀន.– ហៅសិស្សម្នាក់ឲ្យទៅឈរនៅមុខពួកសិស្ស ហើយឲ្យដោះអាវ,ខោចេញ នៅតែខោទ្រនាប់មួយ រួចនាំសិស្សឲ្យពិនិត្យមើលចំណែកផ្សេងៗនៃខ្លួនមនុស្ស ។ ឲ្យសិស្សនោះកំរើកដៃ,ជើង ក្បាល,ដងខ្លួន ។ ឲ្យរាប់សន្លាក់ដៃតាំងពីស្មារហូតដល់ចុងម្រាមដៃ។ល។..

ខ្លួនមនុស្ស មានបីចំណែក គឺក្បាល,ដងខ្លួន,អវយវៈ ។

១ – .ក្បាល .–ក្បាលរាងមូល នៅលើក្បាលមានសក់ដុះ

ឆាសពេញ ដើម្បីនឹងការពារក្បាល ។ នៅខាងមុខ គេឃើញភ្នែកពីរ ប្រមុះមួយ ត្រចៀកពីរនឹងមាត់មួយ ។ ថ្គាមក្រោមមានសន្លាក់សំរាប់កំរើក ផ្ទប់ទៅថ្គាមលើ ។ ពិនិត្យមើលឲ្យឃើញជាក់ ឲ្យសិស្សដាក់ម្រាមដៃទន្ទឹមនឹងត្រចៀកហើយហាមាត់នឹងដឹងថាថ្គាមក្រោមកំរើក ភ្នែក រន្ធប្រមុះ ថ្ពាល់ក៏កម្រើកបានដូចជាថ្គាមក្រោមដែរ ។ ក្បាលបន្តជាប់ទៅដងខ្លួននឹងក កអាចឲ្យក្បាលងៀកទៅឆ្វេងឬស្តាំបានដោយងាយ ។

២–ដងខ្លួន. – ដងខ្លួនមានឆ្អឹងរុំព័ទ្ធជុំវិញ ដូចជាទ្រូងដាក់ត្រ ខាងក្រោយមានឆ្អឹងទ្រនុងខ្នង នៅសងខាងនឹងខាងមុខមានឆ្អឹងជំនីរនឹងឆ្អឹងទ្រូង ។ ដងខ្លួនចែកជា ពីរបំណែក: ខាងលើហៅថា ទ្រូង– នៅក្នុងទ្រូងមានសួតពីរនឹងបេះដូងមួយ ។ ចំណែកខាងក្រោម គឺពោះ នៅក្នុងពោះមានថ្លើមក្រពះបាយ,ពោះវៀនធំ,ពោះវៀនតូច ក្រពះទឹកមូត្រ ។ល។

ដងខ្លួនយើង ថ្វីបើ មានឆ្អឹងខ្នង,ឆ្អឹងជំនីរនឹងឆ្អឹងទ្រូង តែយើងកម្រើកបានតាមចិត្ត ដោយសន្លាក់ឆ្អឹងខ្នង ។

៣ – អវយវៈ. – យើងមានអវយវលើពីរ: គឺដៃពីរ–ក្រោមពីរ គឺជើងពីរ ។ ដៃបន្តជាប់ទៅដងខ្លួននឹងស្មា ជើងជាប់ទៅដងខ្លួននឹង

ត្រគាក ។ អវយវៈនិមួយ ៗ មានសន្លាក់ជាច្រើន សំរាប់កម្រើក, បត់ ហេតុនេះដៃមានដើមដៃ កំភួនដៃ និងដៃ មានម្រាមប្រាំ – ដើមដៃជាប់ទៅកំភួនដៃនឹងសន្លាក់កែងដៃ កំភួនដៃជាប់ទៅដៃ នឹងកដៃ ជើងមានភ្លៅជាប់ទៅកំភួនជើងនឹងសន្លាក់ជង្គង់ កំភួនជើងជាប់ទៅនឹងកជើង នៅចុងជើងនីមួយៗមានម្រាមប្រាំ ជើងទាំងពីរ សំរាប់ទ្រខ្លួនយើង នៅលើដី សំរាប់ដើរ, រត់ ។ល។ ដៃសំរាប់កាន់យកវត្ថុផ្សេង ៗ ។

ខ្លួនយើងមានស្បែករុំព័ទ្ធជុំវិញ កន្លែងខ្លះស្បែកនោះស្តើង ដូចជាខ្នង, មុខ ។ល។ កន្លែងខ្លះទៀតស្បែកក្រាស់ដូចជាបាតដៃ – ជើង ។ ស្បែកនេះមានរន្ធសុះពេញទាំងខ្លួនសំរាប់បញ្ចេញញើស នៅក្រោមស្បែកមានសាច់, សរសៃ, ។ល។

មេរៀនសង្ខេប. – ខ្លួនមនុស្សយើងមានបីចំណែក គឺក្បាល, ដងខ្លួន នឹងអវយវៈ ។ ក្បាលមានមុខនឹងលលាដ៍ក្បាលដែលមានខួរនៅខាងក្នុង ។

ដងខ្លួនជាប់ទៅក្បាលនឹងក ដងខ្លួនមានពីរចំណែក គឺដើមទ្រូងនឹងពោះ ។ នៅក្នុងទ្រូងមានសួតនឹងបេះដូង ។ ក្រពះបាយ, ថ្លើម, ពោះវៀននឹងក្រពះទឹកមូត្រនៅក្នុងពោះ ។ ដើមដៃ កំភួនដៃនឹងដៃ

រួមគ្នាជាអវយវៈលើ ៗ ភ្លៅ កំភួនជើងនឹងជើង ប្រជុំគ្នាជាអវយវៈក្រោម ៗ ខ្លួនយើងមានស្បែករុំព័ទ្ធជុំវិញ ស្បែកនេះមានរន្ធពាសពេញ សំរាប់បញ្ចេញញើស នៅក្នុងស្បែកមានសាច់នឹងសរសៃរុំព័ទ្ធជុំវិញឆ្អឹង ៗ

ពាក្យសួរ .— ខ្លួនមនុស្សយើងមានប៉ុន្មានចំណែក ? ក្បាលមានប៉ុន្មានចំណែក ? គេឃើញមានអ្វីខ្លះនៅមុខ ? នៅលើក្បាល ? ដងខ្លួនមានប៉ុន្មានចំណែក ? មានអ្វីខ្លះនៅក្នុងទ្រូង ? ក្នុងពោះ ? ចូរអធិប្បាយអំពីដៃអ្នក ? ជើងអ្នក ? ។ ល ។

## អាទិត្យទី ២ — អំពីអដ្ឋិសង្ខលិក .

សូមតែងមេរៀននឹងពាក្យសួរផងចុះ តាមរបៀបក្នុងសេចក្តីណែនាំខាងលើនេះ ៗ

# វិធីបង្ការរោគ

## អាទិត្យទី ១— ការថែរក្សាស្បែក

ស្បែកត្រូវស្អាតជាដរាប .— យើងត្រូវសំអាតស្បែកយើង-ជាដរាប ពីព្រោះស្បែកនេះក៏ដកដង្ហើមចេញ-ចូលតាមរន្ធរោមដូចជា-

ប្រមុះដែរ ។ ញើសដែលចេញពីរន្ធរោមបណ្ដាលឲ្យជាប់ធូលីដែលហុយមកប៉ះពាល់ខ្លួនយើង ។ បើយើងមិនងូតទឹកលាងស្បែកយើងឲ្យញយៗទេ ធូលីនេះនឹងបិទរន្ធរោមជិតអស់ ហើយមានក្លិនអាក្រក់ ស្បែកបញ្ចេញញើសពុំបានបណ្ដាលឲ្យយើងឈឺ មួយទៀតសត្វចៃ សង្កើចស្រមើល ចូលចិត្តនៅលើក្បាល, ស្បែកមិនស្អាតនេះ ហើយខាំជញ្ជក់យកឈាមជាអាហារ។ កន្លែងដែលវាខាំជញ្ជក់ឈាមនោះបណ្ដាលឲ្យកើតកមរមាស់ ។ ដូច្នេះយើងត្រូវងូតទឹកដុសលាងសំអាតស្បែកយើងជាញយៗកុំឲ្យក្អែលស្ទះរន្ធរោមបានឡើយ ។

**ត្រូវសំអាតដៃជាដរាប** .– ដៃយើងក៏ត្រូវលាងសំអាតដូចជាស្បែកយើងដែរ ពីព្រោះដៃនេះចាប់កាន់យកអាហារបរិភោគ ឬទៅឈ្លីគ្រប់កន្លែងដោយមានជាប់សត្វមេរោគជាមួយផង សត្វនេះបណ្ដាលឲ្យកើតជម្ងឺក្អកក្រហម ។ ហេតុនេះក្នុងមួយថ្ងៃៗយើងត្រូវលាងដៃឲ្យច្រើនដង ត្រូវលាងដៃនឹងសាប៊ូមុននឹងបរិភោគអាហារ ពីព្រោះសាប៊ូនេះនាំឲ្យកាត់ជាប់វត្ថុដែលជាប់ស្អិតដូចជាខ្លាញ់ជាដើម ហើយនឹងកំចាត់សត្វមេរោគដែលជាប់នៅស្បែកដៃ ។

**ការលាងសំអាតរាល់ថ្ងៃ** .– ត្រូវលាងសំអាតមុខ, ក, ដៃ, ជើង

ពេលល្ងាចមុនដេក តែខ្លួនស្អាតដេកក៏លក់ស្រួល លុះព្រឹកឡើងត្រូវលុបលាងមុខដោយទឹកក្ដៅឧ៎នៗ រួចដុសសំអាតទន្ទឹកនៃស្រង់ពោះគោ ៗ ខ្លួនយើងទៀតក៏ត្រូវងូតទឹកដុសលាងជារាល់ថ្ងៃ ងូតទឹក ដុសសាប៊ូយ៉ាងតិចក្នុងមួយអាទិត្យពីរដង ងូតទឹកសមុទ្រឬទឹកទន្លេជាការសំខាន់ណាស់ដែរ តែមិនត្រូវងូតទឹកត្រពាំងទេ ៗ

**មេរៀនសង្ខេប** .– ស្បែកយើងត្រូវស្អាតជាដរាប ដើម្បីឲ្យបានសេចក្ដីសុខ ៗ ដៃប្រឡាក់បានដោយងាយណាស់ យើងត្រូវលាងដៃឲ្យបានច្រើនដងក្នុងមួយថ្ងៃ ៗ បើហោចណាស់មុននឹងក្រោយដែលបរិភោគអាហារ សាប៊ូជាវត្ថុប្រសើរប្រយោជន៍កំចាត់បង់នៃសត្វមេរោគទាំងពួង ៗ ចំណែកឯខ្លួនប្រាណត្រូវដុសលាងរាល់ថ្ងៃនៅពេលល្ងាច ប៉ុន្តែក្រោយបរិភោគបាយរួច ចំនួនបីម៉ោងយ៉ាងតិចសឹមងូតទឹក ៗ គេពុំត្រូវងូតឲ្យយូរពេកទេ ៗ ងូតទឹកសមុទ្រ ទឹកទន្លេឬហាលទឹកជាការសំខាន់ណាស់ដែរ ៗ

**ពាក្យសួរ** .– ពីព្រោះអ្វីបានជាគេត្រូវថែរក្សាស្បែកឲ្យស្អាតជាដរាប ? ហេតុអ្វីបានជាឲ្យលាងដៃញយ ៗ ? ចំណែកឯទៀតត្រូវសំអាតដែរឬទេ ? នៅវេលាណា ?

— អ្នកចូលចិត្តងូតទឹកក្ដៅឬទឹកត្រជាក់ ? ពីព្រោះអ្វី ? ។ល។-

អាទិត្យទី ២ – សូមលោកគ្រូតែងមេរៀនទាំងពាក្យសួរផងចុះ

មជ្ឈិមដ្ឋានទី ២ – អំពីការសំអាតខ្លួន

ឧត្តមដ្ឋាន – អំពីជម្ងឺភ្នែក

(សូមមើលមេរៀនទាំងពីរ ខាងលើនេះក្នុងសៀវភៅវត្ថុស្វាធ្យាយន៍ ភាសាបារាំងថ្នាក់ឧត្តមដ្ឋាន ) ។

---

## អាទិកដ្ឋាន

### វត្ថុស្វាធ្យាយន៍

អាទិត្យទី ១.– មេរៀនលេខ ១– ខ្លួនមនុស្ស

គ្រូត្រូវយកផ្ទាំងគំនូររូបមនុស្សមកពន្យល់សិស្ស ឬឲ្យសិស្សម្នាក់ ដោះអាវចេញ ស្លៀកតែខោទ្រនាប់ ហើយមកឈរនៅមុខពួកសិស្ស ។ គ្រូ-ចោទសួរហើយនាំសិស្សពិនិត្យមើលឲ្យជាក់ ។ ខ្លួនមនុស្សយើងមាន

ប៉ុន្មានចំណែក ? (មានបីចំណែកគឺ ក្បាល , ដងខ្លួន , និងអវយវៈលើក្រោម) នៅក្បាលមានអ្វីខ្លះ ? យើងអាចចុះឡើងបានឬទេ ? ដោយសារអ្វី ? ដងខ្លួនយើងចែកជាប៉ុន្មានចំណែក ? បង្ហាញចំណែកទាំងពីរនេះ (ទ្រូងហើយនិងពោះ) ។ អវយវៈមានប៉ុន្មាន ? អវយវៈលើ ភ្ជាប់ទៅនឹងដងខ្លួនកន្លែងណា ?(ត្រង់សន្លាក់ស្មា) ។ ដៃយើងបត់បានកន្លែងណាខ្លះ? (សន្លាក់ស្មា ,កដៃ ,ម្រាមដៃ) បើប្រសិនណាជាគ្មានសន្លាក់អស់ទាំងនេះទេ ដៃយើងពុំអាចនឹងបត់ចុះឡើងបានឡើយ ។ អវយវៈក្រោមភ្ជាប់នឹងដងខ្លួនកន្លែងត្រង់ណា ? អវយវៈក្រោមមានប៉ុន្មានចំណែក ? សន្លាក់មានប៉ុន្មាន ?

**សេចក្ដីសង្ខេប .–** ខ្លួនមនុស្សយើងមានបីចំណែកគឺក្បាល ដងខ្លួន និងអវយវៈ ។ កភ្ជាប់ក្បាលទៅនឹងដងខ្លួន ។ នៅក្រោយដងខ្លួនមានឆ្អឹងខ្នង ។ ដងខ្លួនមានពីរចំណែក ៖ ខាងលើគឺទ្រូង, ខាងក្រោមគឺពោះ ។ មានអវយវៈបួនភ្ជាប់នឹងដងខ្លួន ៖ ខាងលើពីរ ខាងក្រោមពីរ ។ ខ្លួនមនុស្សយើងមានសន្លាក់ជាច្រើនប្រយោជន៍នឹងបត់ចុះឡើងបាន ។

## មេរៀនលេខ ២.– អដ្ឋិសង្ខលិក

សៀវភៅគ្រូស្វាធ្យាយទំព័រលេខ ៦ ដល់លេខ ១០ ។

គ្រូត្រូវពន្យល់ដោយសង្ខេប នាំសិស្សឲ្យស្គាល់ឆ្អឹង ឲ្យដឹងច្រើន ក្រោយហើយឲ្យដឹងប្រយោជន៍ឆ្អឹងតាមសណ្ឋាន ៗ

អាទិត្យទី ២ .– ក្នុងអាទិត្យនេះសុំគ្រូពន្យល់ ពីការសំខាន់ៗក្នុងការទ្រទ្រង់ជីវិតយើងគឺ ការរំលាយអាហារ, ការដកដង្ហើម, ការឈាមរត់ក្នុងខ្លួននឹងការបញ្ចេញវត្ថុមិនស្អាតមកក្រៅ ( ញើស - លាមក - ទឹកមូត្រ ) ៗ

មើលសៀវភៅវត្ថុស្វាធ្យាយន៍ទំព័រទី១២ទៅដល់ទំព័រទី១៦ ៗ

---

# មជ្ឈិមដ្ឋាន

អាទិត្យទី១ .– មេរៀនលេខ ១ .– ខ្លួនមនុស្ស

សូមបង្រៀនតាមមេរៀនលេខ១សំរាប់អាទិកដ្ឋាន ហើយបន្ថែមសេចក្តីលើខ្លះទៀត ៗ

អាទិត្យទី២ .– មេរៀនលេខ១ អដ្ឋិសង្ខលិក

សូមមើលក្នុងសៀវភៅវត្ថុស្វាធ្យាយន៍បដិញ្ញាណថានទំព័រទី៦-៧ ៗ

មេរៀនលេខ២.– សាច់ដុំ

សូមមើលក្នុងសៀវភៅដដែលទំព័រទី១១

# អាទិកង្ហាន

## វិធីបង្ការរោគ

### អាទិត្យទី ១.– មេរៀនទី ១– ការសំអាតខ្លួន –

សុំមើលទស្សនាវដ្ដីឆ្នាំ ១៩៤៩ - ៥០, លេខ ១ ទំព័រទី ៤៧ - ៤៨ - ៤៩ ។

### មេរៀនទី ២– ការសំអាតសំលៀកបំពាក់ –

សុំមើលវិធីបង្ការរោគកុមារដ្ឋាននិងបរិច្ឆណដ្ឋានទំព័រ ១៤ - ១៥ – និង ២៨ – ២៩ – ៣០ ( ប្រការ ១ )

### អាទិត្យទី២ មេរៀនទី ១– ការសំអាតសំលៀកបំពាក់ (ត)

សុំមើលវិធីបង្ការរោគថ្នាក់ដដែលទំព័រទី ៣១ – ៣២ ( ប្រការ ២ )

### មេរៀនទី២.– វិធីបង្ការរោគចំពោះផ្ទះ

ត្រូវរើសកន្លែងសង់ផ្ទះ ៖ នៅទីក្រុងត្រូវសង់តាមវិថីធំ ៗ នៅស្រុកស្រែត្រូវរើសទីទួលនៅឆ្ងាយពីទីថ្លុកត្រពាំងបឹងផ្លូវទឹក ៗ គួរសង់ផ្ទះឲ្យបានបែរមុខទៅខាងត្បូង ៗ ដើមឈើដាំឆ្ងាយធ្វើឲ្យអាកាសបរិសុទ្ធហើយតែកុំឲ្យដាំជិតផ្ទះពេក ដើម្បីទុកឲ្យពន្លឺព្រះអាទិត្យនិងអាកាសចូលក្នុងផ្ទះ ៗ

ត្រូវសង់ក្រោលគោ – ក្របី – សេះ – ទ្រុងជ្រូក – មាន់ – ទា នឹងបង្គន់ឲ្យឆ្ងាយពីផ្ទះ ។

រាល់ព្រឹកត្រូវបើកទ្វារបង្អួចទាំងអស់ ត្រូវបោសក្តារក្រោលថ្មមៗកុំឲ្យធូលីហុយឡើងត្រូវជូតគ្រឿងតុតាំងដោយសំពត់សើមត្រូវរើពូក – ខ្នើយ – កន្ទេល – មុងហាលថ្ងៃឲ្យបានញយៗ ។ ត្រូវបោសទីភូមិឲ្យបានស្អាតជានិច្ច ហើយត្រូវដុតសំរាមចោល ។

សុភាសិត – កន្លែងណាដែលមានពន្លឺព្រះអាទិត្យចូល កន្លែងនោះពុំសូវមានមេរោគទេ ។

សុំគ្រូធ្វើពាក្យសួរផងចុះ ។

---

# មជ្ឈិមដ្ឋាន

## វិធីបង្ការរោគ

អាទិត្យទី១ .– មេរៀនទី២និងទី១ ការសំអាតខ្លួន

សុំមើលទស្សនាវដ្តីឆ្នាំ ១៩៤៩ .៥០ លេខ ១ ទំព័រទី ៥២.៥៣

## អាទិត្យទី ២._ មេរៀនទី ១ វិធីហាត់ប្រាណ

សុំមើលទស្សនាវដ្ដីឆ្នាំដដែល ទំព័រទី ៥១

## មេរៀនទី២.- ប្រយោជន៍កើតពីការហាត់ប្រាណ.

សាច់ដុំដែលធ្វើការឡើងធំរឹងហើយខ្លាំង ការហាត់ប្រាណនាំគ្រឿងប្រដាប់ក្នុងខ្លួនយើងឲ្យដើរបានស្រួល នាំឲ្យឃ្លានបាយឲ្យអាហាររលាយបានដោយងាយ ឲ្យអាស្រ័យដំណេកបាន ។ កុមារណាស្រួលខ្លួន កុមារនោះមានទឹកមុខស្រស់មានបញ្ញាថ្លា អាចរៀនអ្វីបានចំរើនមិនធុញទ្រាន់នឹងការសិក្សាឡើយ ។

---

# **កុមារដ្ឋាន**

## វត្តស្វាធ្យាយន៍

## អាទិត្យទី ១ ._ អំពីស្មាំផ្ទៃ

ការបង្រៀនក្នុងខែកញ្ញានេះ សិស្សនៅថ្នាក់កុមារដ្ឋានពុំទាន់ចេះមើលសរសេរនៅឡើយ សុំគ្រូហ្វឹកហ្វឺនឲ្យចាំស្ទាត់តែខាងវិធីហាត់ ហើយនឹងប្រាប់ពន្យល់ឲ្យចាំប្រាកដផង ។

## មេរៀនលេខ ១ ._ អំពីស្តាំឆ្វេង

នាំសិស្សឲ្យពិនិត្យមើលឲ្យដឹងស្តាំឆ្វេង ។ ឯងមានដៃប៉ុន្មាន ? ដៃទាំងពីរនេះមានឈ្មោះឬទេ ? ដៃនេះឈ្មោះដូចម្តេច ? ដៃនេះទៀតឈ្មោះអ្វី ? ដៃទាំងពីរដៃណាធ្វើការច្រើនជាងគេ ? ឲ្យសិស្សលើកដៃទាំងអស់គ្នាតាមគ្រូចោទ ។

នៅខាងស្តាំឯងមានអ្វី ? បើឯងបែរមុខទៅខាងជើង ទិសណានៅខាងស្តាំឯង ? ទិសណានៅខាងឆ្វេងឯង ? ទិសណានៅខាងមុខឯង ? ទិសណានៅខាងក្រោយឯង ? បើឯងដើរតាមផ្លូវ ត្រូវដើរខាងណា ? ចុះបើបររទេះក្តី ជិះសេះក្តី ត្រូវកាន់ខាងណា ?

ពីព្រោះអ្វីបានជាគេឲ្យប្រកាន់ខាងស្តាំយ៉ាងនេះ ? (កុំឲ្យជល់ទង្គិចគ្នាវេលាដែលជួបគ្នា) ចុះបើឯងជិះទូកឬកប៉ាល់ ចុះបណ្តោយតាមទឹក ខាងណាដែលហៅត្រើយស្តាំ ? ត្រើយណាដែលហៅត្រើយឆ្វេង ? ។ល។

## មេរៀនចាំមាត់ - សេចក្តីសង្ខេប

ត្រូវឲ្យស្គាល់ស្តាំឆ្វេង ដៃស្តាំធ្វើការច្រើនជាងដៃឆ្វេង ទៅណាមកណាត្រូវប្រកាន់ខាងស្តាំដរាប ។

## អាទិត្យទី ២០.– អំពីច្បាប់ដើរនៅផ្លូវ

សុំគ្រូរំលឹកសិស្សពីមេរៀនមុន ហើយនាំសិស្សមកប្រាប់របៀបដើរហើយនឹងឆ្លងផ្លូវនៅផ្លូវមុខថ្នាក់ ។

១ – វេលាណាដែលយើងដើរនៅផ្លូវ យើងត្រូវឲ្យចេះច្បាប់ដើរ ពីព្រោះនៅផ្លូវតែងមានគ្រោះថ្នាក់ជានិច្ច លើរូបអ្នកដែលមិនប្រយ័ត្ន នៅទីក្រុងនៅផ្លូវនីមួយ ៗ មានរទេះតិចឬច្រើន ? យើងត្រូវដើរដូចម្ដេចតាមផ្លូវ ? វេលាឆ្លងផ្លូវត្រូវធ្វើដូចម្ដេច ? វេលាឆ្លងផ្លូវមានរទេះបរមកចំខ្លួន ត្រូវជៀសដូចម្ដេច ? មិនត្រូវរត់ឆ្វេងឆ្វាដោយភ័យ ត្រូវគិតមើលឲ្យស្រួល បើគួរឈប់ត្រូវឈប់ ទុកឲ្យរទេះជៀសវិញ បើចង់គេចត្រូវគេចទៅតែខាងស្ដាំ ។

២ – ចោទសួរ បើជិះរទេះកង់ត្រូវប្រកាន់ខាងណា ? បើចង់បត់ឆ្វេងស្ដាំត្រូវធ្វើដូចម្ដេច ? ។ល។

៣ – សេចក្ដីសង្ខេប – ទោះដើរនៅផ្លូវថ្នល់ក្ដី ជិះកង់ក្ដីឬជៀសរទេះឡានក្ដី ក៏គប្បីប្រកាន់ស្ដាំជាដរាប ។

# វិធីបង្ការរោគ

## អាទិត្យទី១.– អំពីការសំអាតខ្លួនប្រាណ

ក្នុងខែនេះដោយសិស្សពុំទាន់ចេះមើលចេះសរសេរនៅឡើយ គ្រូតោងបង្ហាញតែខាងវិធីហាត់ឲ្យមែនទែនហើយនឹងចោទមាត់ទទេឲ្យចាំប្រាកដក្នុងការសំអាតខ្លួន

១– គ្រូចាត់សិស្សម្នាក់ដែលមិនស្អាតឲ្យទៅឈរនៅមុខតុសិស្សឯទៀតៗ រួចហើយនាំសិស្សឯទៀតឲ្យពិនិត្យខ្លួនប្រាណ ដៃជើងមុខមាត់ឲ្យគ្រប់កន្លែង ។ល។

សិស្សដែលឈរនេះឈ្មោះអ្វី ? នៅត្រង់ណាទៀតដែលមានក្អែលច្រើន ? ឯងធុំក្លិនអ្វីកាលឯងមកឈរជិតវា ?

ក្អែលនៅលើស្បែកបិទរន្ធអ្វី ? ក្មេងស្មោកគ្រោកដូចចៅនេះបានសេចក្ដីសុខសប្បាយឬទេ ? វាបង្កើតរោគអ្វី ? ។ល។

ត្រូវធ្វើដូចម្ដេចទើបស្អាត ? ឯងត្រូវងូតទឹកដូចម្ដេច ? កាលងូតទឹកត្រូវដុសសាប៊ូខ្លួនប្រាណដូចម្ដេច ? ត្រូវប្រើអ្វីទើបជ្រះក្អែលល្អ ? បើគ្មានសាប៊ូអ្នកត្រូវយកអ្វីមកប្រើជំនួស ? យ៉ាងហោចក្នុងមួយអាទិត្យត្រូវ

ផុសខ្លួនប្រាណប៉ុន្មានដង? ការសំអាតខ្លួនប្រាណបានប្រយោជន៍ដូចម្ដេចខ្លះ? ។ល។

២_ សេចក្ដីសង្ខេប .- ប្រយោជន៍សុខសាន្ត ត្រូវសំអាតប្រាណ ឲ្យបានហ្មត់ហ្មង ផុសបត្ដូរជើង គ្រប់សារពាង្គផង ទើបរួចកន្លងពីការស្មោកគ្រោក ។

## អាទិត្យទី ២._ របៀបប្រើសាប៊ូ

កាលណាគេបោកលាងសំលៀកបំពាក់តែនឹងទឹកទទេ តើនឹងបានស្អាតឬទេ ? បើដូច្នេះខ្លួនប្រាណយើងក៏ត្រូវផុសលាងនឹងសាប៊ូដែរ កាលណាឯងធ្លូតទឹកសាប៊ូនាំឲ្យកាត់ក្អែល បំបាត់ក្លិនអាក្រក់ គេផុសសំលៀកបំពាក់នឹងសាប៊ូល្អ គេផុសខ្លួនប្រាណនឹង សាប៊ូក្រអូប វេលាដែលផុសសាប៊ូត្រូវផុសឲ្យយូរសឹមលាងទឹកចេញ ។

## អំពើកិច្ច

ធ្វើដូចម្ដេចឲ្យបានទឹកស្អាតសុទ្ធផឹកតាមត្រូវការ ?

យើងយកថ្នាំពែរម៉ង់កាណាត មកលាយនឹងទឹកក៏បានដែរ ប៉ុន្តែអ្នកស្រុកពុំធ្លាប់ប្រើ តាមធម្មតាគេយកទឹកមកដាំឲ្យពុះចំនួន១៥ មីនុត ទើបយកមក

ផឹក  ការទំលាប់ផឹកទឹកក្តៅនេះ  នាំឲ្យយើងជៀសវាងជម្ងឺច្រើនប្រការ កាលណាស្រុកមានជម្ងឺ ។ យើងបង់ឲ្យទឹកក្តៅនោះមានក្លិនរសជាតិល្អ ត្រូវធ្វើដូចម្តេចទៀត ? យួនមិនប្រើទឹកតែជាប់ជាធម្មតា ។ ខ្មែរយើងក៏ប្រើដែរ ខ្លះប្រើទឹកឫសជន្ហិតស្ងោរឬឫសអណ្ដូងព្រះ ។ ទំលាប់យ៉ាងនេះជាការសំខាន់ ព្រោះភេសជ្ជៈនេះមានគុណប្រយោជន៍ហើយថ្លៃតិចផង ។

---

# បរិច្ឆេទផ្សេង

## វិត្តស្វាធ្យាយន៍

### អាទិត្យទី ១.— អំពីខ្លួនមនុស្ស

១ — គ្រូត្រូវយកផ្ទាំងគំនូររូបមនុស្សមកបង្ហាញសិស្សឲ្យស្គាល់ចំណែកខ្លួនមនុស្ស រួចហៅសិស្សម្នាក់មកឈរពីមុខតុសិស្ស ហើយឲ្យដោះអាវចេញ ហៅសិស្សឯទៀត ៗ ឲ្យពិនិត្យ មើលចំណែករូបកាយយើង ហើយចោទសួរបណ្ដើរ តាមរបៀបដូចមាននៅក្នុងសៀវភៅ

វត្ថុសាធ្យាយន៍បរិច្ចណដ្ឋានទំព័រទី ៣ និងទី ៤ មានទាំងពាក្យសួរនិងមេរៀនសង្ខេបសំរាប់ឲ្យសិស្សរៀនស្រាប់ហើយ ។

២– អដ្ឋិសន្ធិលិក ក្បាល ដងខ្លួននិងអវយវៈ

បើគ្មានផ្ទាំងគំនូរទេ ត្រូវនាំសិស្សឲ្យមើលគំនូរក្នុងសៀវភៅ រួចឲ្យស្ទាបបង្ហាញលើខ្លួនសិស្ស ដែលដោះអាវនៅឈរពីមុខគេនោះ ហើយឲ្យប្រាប់ឈ្មោះឆ្អឹង ទ្រង់ទ្រាយនិងទំហំឆ្អឹង ហើយនិងប្រយោជន៍ឆ្អឹង ហេតុដូចម្ដេចបានជាមានឆ្អឹងខ្លះមូល ឆ្អឹងខ្លះសំប៉ែត ឆ្អឹងខ្លះវែង ឆ្អឹងខ្លះខ្លី?

សុំមើល·សេចក្ដីនេះនៅក្នុងសៀវភៅដដែលទំព័រទី ៥ និងទី ៦ ។

## អាទិត្យទី ២.– អំពីឆ្អឹងសន្លាក់ឬគណ្ឋិក

សុំមើលក្នុងសៀវភៅដដែលទំព័រទី ៨ និងទី ៩ ។

## អំពីសាច់ដុំ

សុំមើលសៀវភៅដដែលទំព័រទី ១០ ។

# វិធីបង្ការរោគ

## អាទិត្យទី ១.– វិធីហាត់ប្រាណ

ឲ្យសិស្សពិនិត្យមើលរូបពង់កាយអ្នកស្រែចំការ  នឹងអ្នកធ្វើការរាជការ តើខុសគ្នាយ៉ាងណា ? ដោយសារអ្វី ? បើដូច្នេះត្រូវធ្វើដូចម្ដេចឲ្យបានរូបកាយធាត់ធំមាំមួន ? ត្រូវហាត់ប្រាណនៅទីណា ? នៅពេលណា ? ក្នុងពេលហាត់ប្រាណមិនត្រូវធ្វើកាយមាយឲ្យសោះ ៗ ត្រូវខំប្រឹងប្រែងឲ្យមាំមួន ទើបបានរូបកាយនោះសមល្អហើយជម្ងឺរោគាក៏មិនអាចនឹងបៀតបៀនបានផង ។

ម្យ៉ាងទៀតត្រូវហាត់ដើរក្នុង ១ ថ្ងៃឲ្យបាន ២ ម៉ោង ដេកពីព្រលប់ក្រោកពីព្រលឹម ឲ្យខ្យល់អាកាសចូលក្នុងដំណេកឲ្យបរិបូណ៌ . ។

មេរៀនសង្ខេប .— សុំគ្រូតែងផងចុះ ។

## អាទិត្យទី ២ . — ការសំអាតខ្លួនប្រាណ

កាលណាឯងរត់លេងហាលក្ដៅ ឯងឃើញមានអ្វីនៅលើស្បែកឯង ? ឲ្យសិស្សយកដៃជូតមុខវាយកមកមើល តើវាឃើញមានអ្វី ? ញើសស្អិតដូចប្រេង ៗ ឲ្យវាលិទ្ធមើលតើទឹងជឹងដូចម្ដេច ? ប្រៃ ៗ ហិតក្លិនមើលៗ ធុំអ ក្រក់ ៗ កាលណាធូលីហុយមកប៉ះទឹងបង្កើតទៅជាអ្វី ? ក្អែល ៗ ក្អែលបណ្ដាលឲ្យបានយ៉ាងណា ? ចុករន្ធញើសមិនឲ្យចេញ ៗ មនុស្ស

ណាដែលញើសមិនចេញតើស្រួលខ្លួនឬទេ ? បើចង់ឲ្យញើសចេញស្រួលត្រូវធ្វើដូចម្ដេច ។

មេរៀនសង្ខេប.— មនុស្សយើងត្រូវថែរក្សាស្បែកឲ្យស្អាត ពីព្រោះស្បែកនេះហើយ ដែលជាប្រដាប់សំរាប់បញ្ចេញញើស ដែលជាវត្ថុសៅហ្មងដល់រូបកាយយើង ហេតុនេះត្រូវដុសលាងនឹងសាប៊ូជារឿយ ៗ ត្រូវលាងដៃឲ្យស្អាត ៗ ក្រចកដៃ ក្រចកជើងត្រូវកាត់ឲ្យខ្លី ៗ

## មេសូត្រត់មាត់

(សំរាប់គ្រប់ថ្នាក់)

### ១.— ត្រូវខំរៀនសូត្រ

យើងសូមរំលឹកដល់កុមារ ដែលបានសិក្សាខាងវិជ្ជា
ចូរនាងខំប្រឹងទាំងអស់គ្នា កុំខ្ជិលរៀនធុញថប់អ្វី ។
នាងអើយមនុស្សយើងក្នុងលោកនេះ ត្រូវរៀនឲ្យចេះទាំងប្រុសស្រី
ចំណេះនេះហើយគេឮឈ្មោះល្បី ពីបាកម្ដេចក៏ខំរៀនទៅ ។

ពាក្យពន្យល់.— វិជ្ជា=ចំណេះ ។ ក្នុងលោក=ឋានមនុស្ស ។

កេរ្តិ៍ឈ្មោះ=សេចក្ដីសរសើរនូវឈ្មោះ ឬវិជ្ជាណាមួយៗ ។

នាងអើយអានថា: នាងអ៊ើយ-

## ២- ត្រូវខំរៀនសូត្រ (ត)

ប្រឹងរៀនគង់តែមានដំរិះ យូរធ្លាប់គង់ចេះដឹងត្រឹមត្រូវ
បើនាងរៀនបានចេះគ្រប់ផ្លូវ បាននៅដោយសុខស្រណុកកាយ ។
អ្នកនឹងបានធ្វើជាមន្ត្រី កេរ្តិ៍ឈ្មោះក៏ល្បីឮសុសសាយ
មានទ្រព្យសម្បត្តិមិនខ្វះចាយ អ្នកផងទាំងឡាយខ្លាចគ្រប់គ្នា ។
ខ្ជិលរៀននាងអើយមិនដែលចេះ មនុស្សគ្មានចំណេះតែងវេទនា
រកស៊ីពិបាកគ្រប់វេលា ខ្វះក្រទៅជាដើរលួចប្លន់ ។

ពាក្យពន្យល់.- កាយ= រូបដែលជាទីប្រជុំអាការ ៣២ មាន សក់, រោម, ក្រចកជាដើម . . . . . ។ មន្ត្រី= នាម៉ឺន ។ ទ្រព្យសម្បត្តិ= អម្រស់= របរ, មុខការរបរ ។ ទាំងឡាយ= ទាំងអស់ ។

# ៣ – ត្រូវមកសាលារៀនឲ្យទាន់ពេលវេលា

ព្រឹកព្រាងនាងភ្ញាក់វេលាណា ត្រូវតែកុមារក្រោកម្មីម្មា

កុំដេកដំអក់ឲ្យយូរយារ ទោះជាមិនទាន់បាត់ងុយក្តី ៗ

ត្រូវតែលុបមុខលាងខ្លួនប្រាណ សិតសក់ឲ្យបានស្អាតប្រពៃ

ស្លៀកពាក់គាន់សៀវភៅចុះដី កុំបីបង្អង់នៅរេព ៗ

ចេញទៅនាងត្រូវដើរឲ្យឆាប់ ប្រញាប់ឲ្យទាន់ពេលវេលា

មិនត្រូវឈប់នៅប្រឡែងគ្នា ទោះជាមិនទាន់ទូងស្គរក្តី ៗ

ត្រូវតែខំដើរស្រូតរូតទៅ ដល់បង្អង់នៅឥតគិតអ្វី

ដល់ពេលចូលរៀនយើងគ្មានភ័យ ព្រួយនឹងគ្រូស្តីដៀលត្មះថា ៗ

បើសិនជានាងបង្អង់នៅ ឮស្គរទើបទៅចូលសាលា

ទោះជានាងប្រញាប់យ៉ាងណា គង់តែកុមារទៅមិនទាន់ ៗ

ពាក្យពន្យល់ ៖ – ព្រឹកព្រាង = វេលាដែលព្រះអាទិត្យទើបរះ

ព្រាង ៗ ៗ ដេកដំអក់ = ដេកក្រេក្រោក ៗ

ខ្លួនប្រាណ = ( ខ្លួន=ពាក្យសម្រួលមាត់ ) គឺខ្លួន.)ៗ

ទូង ឬ ទួង = វាយ ( ទូងស្គរ = វាយស្គរ

## ៤ – ប្រយោជន៍សាលារៀន

រាជការបានបង្កើតសាលា បង្រៀនកុមារទាំងប្រុសស្រី
ស្ទើរតែគ្រប់ទីក្នុងបុរី ដើម្បីឲ្យចេះមើលសរសេរ ។
រៀនលេខនឹងរៀនក្បួនទន្ត បូកបង់ចែកគុណកុំទំនេរ
បើសិនណាបង់ផ្លួញនឹងគេ ចេះមេគិតចំណេញខាតបាន ។
ដឹងទាំងវិធីបង្ការរោគ ដែលបង្កើតមកឈឺដល់ប្រាណ
ផលលើព្រះធរណីប៉ុន្មាន យើងបានដឹងគ្មានសល់ត្រង់ណា ។
ហេតុនេះត្រូវខំរៀនចំណេះ តែចេះមាំមួនបានធ្វើការ
នឹងបានបៀវត្សក្នុងរាជការ ចិញ្ចឹមអាត្មារៀងទៅ ។
បើអ្នកមិនបានរៀនចំណេះ ធំទៅគ្មានចេះដឹងខុសត្រូវ
រកស៊ីវេទនាហាលថ្ងៃក្តៅ លំបាកដល់ទៅកូនប្រពន្ធ ។

ពាក្យពន្យល់ .– បុរី = ក្រុង ឬ ខែត្រធំ ។ ព្រះធរណី = ដី ។
បៀវត្ស = ប្រាក់រង្វាន់ឆ្នាំ ប្រាក់ខែ ។ អាត្មា = ខ្លួន

# លោកនីតិ

ច្បាប់នេះប្រពៃណាស់ អាចឲ្យយើងដឹងរបៀបរាជការផ្សេង ៗ នឹងច្បាប់ទម្លាប់ដែលមានបញ្ញត្តិដល់ពលរដ្ឋទាំងពួង ដែលត្រូវគោរពប្រតិបត្តិតាម ។

នឹងបង្រៀនសិស្សអំពីវិជ្ជានេះ គ្រូត្រូវនិយាយពន្យល់បណ្ដើរ សួរចោទសិស្សបណ្ដើរ ឲ្យសិស្សយល់ហើយចាំប្រាកដ រួចសឹមសរសេរសេចក្ដីសង្ខេបដាក់ឲ្យសិស្សរៀនតាមធម្មតា ។

## សំរាប់ថ្នាក់ ទាំង ៤

## ពីបវរិប្បណ្ណដ្ឋាន ទៅដល់ ឧត្ដមដ្ឋាន

### អាទិត្យដំបូង ប្រទេសកម្ពុជា

កម្ពុជាគឺជាផែនដីមួយកន្លែងក្នុងសកលលោក ជាប្រទេសរបស់ខ្មែរ មានព្រះមហាក្សត្រិយ៍សោយរាជ្យ ៗ របៀបរាជការក៏មានគ្រប់គ្រាន់ដូចប្រទេសដទៃដែរ គឺមានរដ្ឋសភា-ក្រុមព្រះរាជអាណាចក្រ.រដ្ឋាភិបាលនឹងតុលាការ ៗ

រដ្ឋសភាគឺទីប្រជុំអ្នកតំណាងរាស្ត្រ សំរាប់ប្រឹក្សាច្បាប់ទំនុកបំរុងប្តូរគ្រប់គ្រងរដ្ឋ ។ ក្រុមព្រះរាជអាណាចក្រត្រូវពិនិត្យនឹងឲ្យយោបល់អំពីសេចក្តីព្រាងច្បាប់នឹងស្នើច្បាប់ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រមរួចហើយរដ្ឋាភិបាលគឺគណៈរដ្ឋមន្ត្រី នៃព្រះមហាក្សត្រិយ គឺមន្ត្រីទំនុកបំរុងប្រទេស មានចំនួនយ៉ាងច្រើនត្រឹមដប់ពីររូបរាប់បញ្ចូលទាំង រដ្ឋលេខាធិការផង តុលាការគឺក្រសួងជំរះក្តីស្ទង់ថ្លឹងការមិនឲ្យល្អៀង ។

ពាក្យសួរ.– ប្រទេសកម្ពុជា ប្រទេសរបស់ជាតិណា ? ព្រះមហាក្សត្រិយព្រះនាមអ្វី ? របៀបរាជការអ្វីខ្លះដែលអ្នកស្គាល់ ? រដ្ឋសភាសម្រាប់ធ្វើអ្វី ? ។ល។

មេរៀនសង្ខេប.– ប្រទេសកម្ពុជា ជាប្រជាជាតិមួយក្នុងសកលលោក មានមហាក្សត្រិយសោយរាជ្យ ។ ឯរបៀបរាជការក៏មានគ្រប់គ្រាន់ពេញលេញដូចប្រទេសដទៃដែរ មានរដ្ឋសភាក្រុមព្រះរាជអាណាចក្ររដ្ឋាភិបាលនឹងតុលាការ ។

អាទិត្យក្រោយ.– អំពីភូមិនឹងឃុំ

តំបន់ណាដែលមានប្រជុំផ្ទះលំនៅច្រើន ហៅថាភូមិ ។

ភូមិរួមគ្នាពីរបួបីឡើងទៅ បានជាឃុំមួយ មានមន្ត្រីម្នាក់នាយកត្រួតត្រាហៅថាមេឃុំ ។ នៅក្រុងភ្នំពេញគេចែកឃុំជាសង្កាត់ៗ ។ អ្នកត្រួតត្រាសង្កាត់និមួយ ហៅថាមេសង្កាត់ ។

មេឃុំមានស្មៀនទីជំទប់ជួយធ្វើការ ទារពន្ធដារពីរាស្ត្រតាមច្បាប់បញ្ញត្តិ ។ មេឃុំជាអាណាព្យាបាលលើឃុំជួយទំនុកបំរុងរាស្ត្រឲ្យបានសន្តិ-សុខ ។

ពាក្យសួរ .— អ្នកនៅភូមិណា ? ពីព្រោះអ្វីបានគេហៅឈ្មោះភូមិអ្នកយ៉ាងដូច្នេះ ? ភូមិអ្នកតូចឬធំ ? មានមនុស្សនៅប្រហែលប៉ុន្មាននាក់ ? ពីព្រោះអ្វីបានជាគេកសាងភូមិអ្នកនៅទីនោះ ? អ្នកណាដែលត្រួតត្រាលើភូមិអ្នក ? យ៉ាងដូចម្តេចដែលហៅថាឃុំ ? មេឃុំធ្វើអ្វីខ្លះ ? ។ល ។

មេរៀនសង្ខេប .— ភូមិ គឺតំបន់ដែលមានប្រជុំផ្ទះលំនៅច្រើន ភូមិណាធំទូលាយ មានផ្លូវគាន់គ្នាទៅវិញទៅមកបានដោយងាយ ភូមិនោះមានមនុស្សនៅច្រើនជាងគេ ។

ឃុំគឺទីប្រជុំភូមិច្រើនឬតិចតាមបញ្ញត្តិរាជការរដ្ឋបាល នាទីក្នុងអំណាចមេឃុំម្នាក់ ។ មេឃុំជាអាណាព្យាបាលលើ ការពាររាស្ត្រឲ្យបានសន្តិសុខ មានស្មៀនទីជំទប់ជួយធ្វើការទារពន្ធដារពីរាស្ត្រ តាមច្បាប់បញ្ញត្តិ ។

រោងពុម្ពខ្មែរ-ភ្នំពេញ